ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២៩ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

០៨–៥–១៩៩៥ – ព្រះរាជក្រម លេខ នស/រកម/០៥៩៥/០២ ច្បាប់ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀងឥណទាន ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារ អភិវឌ្ឍន៍អាស៊ី ១៣២៣

II .ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១២–៨–១៩៩៥ – អនុក្រឹត្យលេខ ៨៦ អនក្រ. ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣៨០

២-សេចក្តីប្រកាស

១៥–៨–១៩៩៥ – ប្រកាសលេខ ០៤ ប្រក. សេចក្តីប្រកាស របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ១៣៨១

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១១–៨–១៩៩៥ – ប្រកាសលេខ ១០៣ សហវ.ប្រក.ប ស្តីពីការប្រគល់ភារកិច្ច សំរួលភារកិច្ច និង បន្ទុយឋានៈមន្ត្រីរាជការ រតនាគារ ខេត្ត ក្រចេះ ១៣៨២

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១០-៨-១៩៩៥ – ប្រកាសលេខ ១៨១/៩៥ ពម.ប្រក អនុញ្ញាតអោយសារពត៌មាន «នគរខ្មែរ» ដំណើរការបោះពុម្ពផ្សាយដែលមានលោក នូ គីមអ៊ី ជាចាងហ្វាងការផ្សាយ ១៣៨៥

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១-សេចក្តីណែនាំ

០៩-៨-១៩៩៥ –សេចក្តីណែនាំលេខ ០៥ សណន ស្តីពីការអនុវត្តន៍រៀបចំជ្រើសរើសបវរកញ្ញាកម្ពុជាប្រចាំឆ្នាំ ១៩៩៦ នៃព្រះរាជាណាចក្រកម្ពុជា ១៣៨៦

២-ប្រកាស

១១-៨-១៩៩៥ – ប្រកាសលេខ ១៤៦ ប្រក ស្តីពីការបង្កើតគណៈកម្មការកណ្តាល និង អនុគណៈកម្មការជំនួយការ សំរាប់ការរៀបចំការប្រឡងជ្រើសរើសមវរកញ្ញា នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំឆ្នាំ ១៩៩៦ ១៣៩៤

១២-៨-១៩៩៥ – ប្រកាសលេខ ១៤៧ ប្រក.វវស.បុ ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តស្វាយរៀង ១៤០២

-៨-១៩៩៥ – ប្រកាសលេខ ១៤៨ ប្រក.វវស.បុ ស្តីពីការផ្អាកការងាររួយរយៈដោយពុំទទួលបៀវត្ស ១៤០៣

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

១០-៨-១៩៩៥ – ប្រកាសលេខ ៥៨២ សក.អជជ.តពយ ស្តីពីការធ្វើអាជីវកម្មសាលាបង្រៀនបើកបររថយន្ត ១៤០៤

៥-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

១២-៨-១៩៩៥ – ប្រកាសលេខ ១៤២៨ បស្ថ ស្ដីពីការផ្ទេរភារកិច្ចជូនមន្ត្រីរាជការ ១៤០៩

៦-ទីស្ដីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

១០-៨-១៩៩៥ – ប្រកាសលេខ ១៦៦/៩៥ កធស ប្រក ស្ដីពីការទទួលស្គាល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង ១៤១១

១០-៨-១៩៩៥ – ប្រកាសលេខ ១៦៧/៩៥ កធស. ប្រក ស្ដីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួង ១៤១២

១២-៨-១៩៩៥ – ប្រកាសលេខ ១៦៨/៩៥ កធស. ប្រក ប្រកាសកែតំរូវ ១៤១៣

៧-ទីស្ដីការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្ដីសំរេច

០៩-៨-១៩៩៥ – សេចក្ដីសំរេចលេខ ៥១៤ សសរ. កសក ស្ដីពីការប្រគល់សិទ្ធិអោយអ្នកដែលដេញថ្លៃឈ្នួលឡូត៍នេសាទបានធ្វើអាជីវកម្មក្នុងឡូត៍នេសាទខេត្តកណ្ដាល ព្រៃវែង ពោធិសាត់ បាត់ដំបង សំរាប់រដូវនេសាទ ១៩៩៥-៩៦ និង ១៩៩៦-៩៧ ១៤១៤

៧-រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា

ប្រកាស

១៤-៨-១៩៩៥ – ប្រកាសលេខ ០០៥ ទជស. ប្រក. ស្ដីពីការកំណត់បណ្ដោះអាសន្នតួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋាន និង អង្គភាពចំណុះ ១៤១៦

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

ព្រះរាជក្រមលេខ នស/រកម/០៥៩៥/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីប្រកាសបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀង ឥណទាន ចុះថ្ងៃ ទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្ដីពី

ការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទាន

ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥

រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី

មាត្រា ១: ផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានដែលរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) **នូវទឹកប្រាក់ចំនួន** ១៩.១៩៧.០០០ SDR (ដប់ប្រាំបួនលានមួយ រយកៅសិបប្រាំពីរពាន់ អេស ឌី អរ) តាមឥណទានលេខ ១៣៤៥ CAM (SF) ដើម្បីបំរើគំរោងការ ស្ដារនិងអភិវឌ្ឍន៍អគ្គិសនី ។

មាត្រា ២: ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២
ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួង
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា
នរោត្តម រណឬទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា
ហ៊ុន សែន

* * *

ឥណទានលេខ ២៦៦៤ KH

កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

«គំរោងជំនួយការ - បច្ចេកទេស»

រវាង

ព្រះរាជាណាចក្រកម្ពុជា

និង

សមាគម អភិវឌ្ឍន៍អន្តរជាតិ

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ១៦ ធ្នូ ឆ្នាំ ១៩៩៤

សមាគមអភិវឌ្ឍន៍អន្តរជាតិ
វិថីលេខ ១៨១៨ H. N. W
វ៉ាស៊ិនតោន ឌីស៊ី ២០៤៣៣
សហរដ្ឋអាមេរិក

យោង : ឥណទានលេខ ២៦៦៤ KH
(គំរោងជំនួយការបច្ចេកទេស)
ផ្នែក ៩.០២ នៃល័ក្ខខណ្ឌទូទៅ
ទិន្នន័យហិរញ្ញវត្ថុ និង សេដ្ឋកិច្ច

អស់លោក ជាទីគោរព !

អនុលោមតាមឥណទានសំរាប់ព្រះរាជាណាចក្រកម្ពុជា ត្រូវនឹងទឹកប្រាក់ជារូបិយវត្ថុផ្សេងៗគ្នាសមមូលនឹង ១១.៦០០.០០០ SRD សំរាប់គំរោងជំនួយការបច្ចេកទេស តាងនាមព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយសសូមជំរាបអស់លោកដូចតទៅ :

១–យើងយល់ច្បាស់ និង ឯកភាពថា ក្នុងគោលបំណងទាំងឡាយបានចែងក្នុងផ្នែកនៃ ៩.០២ លក្ខខ័ណ្ឌទូទៅ ដែលអាចអនុវត្តបានចំពោះឥណទានអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជាត្រូវបានសំណូមពរដោយសមាគមន៍អោយផ្ញើរបាយការណ៍ថ្មី «កិច្ចសន្យាបំណុលថ្មី» (ដូចបានបញ្ជាក់ក្នុងរបាយការណ៍ ស្តីពីបំណុលរបស់ធនាគារ ចុះខែ មករា ឆ្នាំ ១៩៨៩) អោយបានមុន ៣០ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាស ក្នុងកំឡុងពេលដែលបំណុលបានកើតឡើងរួចហើយ និងរាយការណ៍ «ទំនាក់ទំនងក្រោមរូបភាពបំណុល» (ដូចបានបញ្ជាក់) អោយបានមុនថ្ងៃទី ៣១ មីនា នៃឆ្នាំ ។

២–សូមបញ្ជាក់ថា គ្មានកំហុសណាយមួយកើតឡើងក្នុងការអនុវត្តបំណុលសាធារណៈក្រៅប្រទេស ។ យើងជឿជាក់ថា ក្នុងការផ្ញើឥណទាន សមាគមត្រូវផ្អែកតាមរបាយការណ៍ ឬ ក៏ផ្អែកតាមលិខិតនេះ ។

ព្រះរាជាណាចក្រកម្ពុជា
ដោយ **គាត ឈន់**
តំណាងរាជរដ្ឋាភិបាល

កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

កិច្ចព្រមព្រៀងចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា ហៅកាត់ «អ្នកខ្ចី» និងសមាគមអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ «សមាគមន៍» ។

«ក» អ្នកខ្ចីមានសោមនស្សរីករាយលើលទ្ធភាព និង អាទិភាព នៃគំរោងដែលបានពិពណ៌នាក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀងនេះ បានស្នើសុំដល់សមាគមរួមវិភាគទានផ្នែកហិរញ្ញវត្ថុ នៃគំរោង

«ខ» សមាគមបានឯកភាពពង្រីកឥណទានដល់អ្នកខ្ចី លើមូលដ្ឋានផ្សេងៗ តាមប្រការ និង លក្ខខ័ណ្ឌទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀង ។

ភាគីទាំងសងខាងបានឯកភាពដូចខាងក្រោម :

មាត្រា I

លក្ខខ័ណ្ឌទូទៅ និយមន័យ

ផ្នែក ១.០១ : លក្ខខ័ណ្ឌទូទៅ អនុវត្តលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍របស់សមាគម ចុះថ្ងៃទី ០១-០១-៨៥ គ្រប់ឃ្លាចុងបង្អស់នៃផ្នែក ៣.០២ ដែលបានលុបចោល លក្ខខ័ណ្ឌទូទៅបង្កើតបានជាកិច្ចព្រមព្រៀងនេះ ទាំងស្រុង ។

ផ្នែក ១.០២ : លើកលែងតែមានសំណូមពរជាក់ស្តែងផ្សេង ៗ ប្រកាសជាច្រើនដែលបានកំណត់ក្នុងលក្ខខ័ណ្ឌទូទៅ និង ក្នុងបុព្វកថា នៃកិច្ចព្រមព្រៀងដែលមានន័យទាក់ទងព្រមទាំងមានបន្ថែមប្រការដែលមានន័យដូចខាងក្រោម :

ក-«កអក» មានន័យថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង្កើតឡើងផ្អែកតាមច្បាប់វិនិយោគទុនរបស់អ្នកខ្ចី នៃ «ព្រះរាជាណាចក្រកម្ពុជា» មានប្រសិទ្ធភាពអនុវត្តនៅថ្ងៃទី ០ សីហា ឆ្នាំ ១៩៩៤

ខ-«កច» មានន័យថា ក្រុមប្រឹក្សាអ្នកច្បាប់របស់អ្នកខ្ចីបង្កើតឡើងអនុលោមតាមអនុក្រឹត្យ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៣ ចុះថ្ងៃទី ១០-៣-១៩៩៤

គ-«គណ» មានន័យថា គណៈរដ្ឋមន្ត្រីរបស់អ្នកខ្ចីបង្កើតឡើងផ្អែកតាមក្រឹត្យ ចុះថ្ងៃទី ០១-១១-១៩៩៣

ឃ-«ឆ្នាំសារពើពន្ធ» មានន័យថា រយៈពេល ១២ ខែ ទាក់ទងទៅនឹងឆ្នាំសារពើពន្ធរបស់អ្នកខ្ចីណាមួយដែលរយៈកាលកំណត់ចាប់ផ្តើមពី ១ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃ ឆ្នាំប្រតិទិននិមួយៗ

ង-«គអក» មានន័យថា គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងផ្នែកកែទំរង់រដ្ឋបាល បង្កើតឡើងយោងតាមអនុក្រឹត្យលេខ ២៣ ចុះថ្ងៃទី ០៩ ឧសភា ១៩៩៤

ច-«អកច» មានន័យថា អង្គភាពកែទំរង់ច្បាប់ត្រូវបានបង្កើតឡើងដោយអ្នកខ្ចីក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាអ្នកច្បាប់យោងតាមប្រការដែលបានចែងក្នុងផ្នែក ៣.០៥ «ក» នៃកិច្ចព្រមព្រៀងនេះ

ឆ-«សហវ» មានន័យថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់អ្នកខ្ចី

ជ-«ពណ» មានន័យថា ក្រសួងពាណិជ្ជកម្មរបស់អ្នកខ្ចី

ឈ-«យធ» មានន័យថា ក្រសួងយុត្តិធម៌របស់អ្នកខ្ចី

ញ-«ធជក» មានន័យថា ធនាគារជាតិ នៃកម្ពុជារបស់អ្នកខ្ចី

ដ-«អគគ» មានន័យថា អង្គភាពគ្រប់គ្រងគំរោង បង្កើតឡើងដោយអ្នកខ្ចី ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុលោមតាមប្រកាសលេខ ២៨៩ ប្រក ចុះថ្ងៃទី ២៨ វិច្ឆិកា ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឋ-«ភ្នាក់ងារគំរោង» មានន័យថា ក្រសួងស្ថាប័ន និង ភ្នាក់ងារនានារបស់អ្នកខ្ចីដែលមានភារកិច្ច ជួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុវត្តគំរោង ។ ភ្នាក់ងារគំរោងទាំងនេះត្រូវផ្អែកតាមឧបសម្ព័ន្ធ ក្នុងកម្មវិធី ២ របស់កិច្ចព្រមព្រៀងនេះ ។

ឌ-ផែនការអនុវត្តគំរោងមានន័យថា ផែនការសំរាប់អនុវត្តគំរោងរបស់អ្នកខ្ចី ហើយត្រូវបានផ្អែកតាមក្នុងផ្នែក ៣.០១ (២) និង មានចែងក្នុងកម្មវិធី ៥ ក្នុងកិច្ចព្រមព្រៀង ។

ឍ-«គណនីពិសេស» មានន័យថា ជាគណនីដែលបានចែងក្នុងផ្នែក ២.០២ (២) របស់កិច្ចព្រមព្រៀង ។

មាត្រា II

ឥណទាន

ផ្នែក ២.០១ : សមាគមឯកភាពផ្តល់អោយអ្នកខ្ចី លើលក្ខខ័ណ្ឌ និង ប្រការទាំងឡាយដែលបានចែង ឬ តាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នេះ លើចំនួនទឹកប្រាក់មួយជា រូបិយវត្ថុផ្សេងៗ គ្មានសមមូលនឹងចំនួន ដប់មួយលានប្រាំមួយរយពាន់ SDR «១១,៦០០,០០០ » ។

ផ្នែក ២.០២(ក) : ចំនួនទឹកប្រាក់នៃឥណទាន ដែលអាចដកគណនីឥណទាន អនុលោមតាមប្រការទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀងឥណទាន សំរាប់យកមក

ចំណាយ ឬ ត្រូវបានចំណាយក្រោយពីបានឯកភាពពីសមាគមត្រូវគោរពតាមគំលៃសមហេតុផល របស់ទំនិញ សេវា ដែលត្រូវការរបស់គំរោងដូចបានចែងក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀង ព្រមទាំងត្រូវបានផ្តល់ហិរញ្ញប្បទានពេញពីចំនួនទឹកប្រាក់ នៃឥណទាន ។

(ខ): ដើម្បីគោលដៅនៃគំរោងអ្នកខ្ចីត្រូវបើកគណនីពិសេសមួយ ជាដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា លើលក្ខខ័ណ្ឌដ៏ប្រសើររបស់សមាគម ដោយប្រព្រឹត្ត ... រួមការពារទប់ទល់ការប៉ះប៉ូវ រឹបអូស ។ ប្រាក់តំកល់ និង ការទូទាត់ តាមរយៈគណនីពិសេសនេះនឹងប្រព្រឹត្តនៅត្រឹមត្រូវតាមខ្លឹមសារដែលបានចែកក្នុងកម្មវិធី ៤ នៃកិច្ចព្រមព្រៀងនេះ ។

ផ្នែក ២.០៣ : កាលបរិច្ឆេទបញ្ចប់ឥណទានត្រូវបានគ្រោង នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១ ឬ អាចក្រោយកាលបរិច្ឆេទនេះ យោងទៅលើសមាគម ។ សមាគមនឹងជូនដំណឹងស្តីពី កាលបរិច្ឆេទថ្មីដល់អ្នកខ្ចី អោយបានឆាប់រហ័ស ។

ផ្នែក ២.០៤(ក) : អ្នកខ្ចីត្រូវបង់ជូនសមាគម នូវបន្ទុកកិច្ចសន្យាតាមអត្រាមួយដែលកំណត់ដោយសមាគមលើចំនួនទឹកប្រាក់នៃឥណទានដែលមិនទាន់បានដកប្រើ នៅថ្ងៃទី ៣០ ខែ មិថុនា រៀងរាល់ឆ្នាំ ក៏ប៉ុន្តែអត្រានោះមិនអោយលើសពីពាក់កណ្តាលនៃ មួយភាគរយក្នុងមួយឆ្នាំ ។

(ខ): បន្ទុកកិច្ចសន្យាចាប់គិតពី ៦០ ថ្ងៃ (i) បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមាន ទៅទល់នឹងកាលកំណត់មួយដែលចំនួននោះ ត្រូវបានដកដោយអ្នកខ្ចីពីគណនីឥណទាន ត្រូវបានលុបចោល ។ (ii) និង តាមអត្រាកំណត់ក្នុងថ្ងៃទី ៣០ មិថុនា ក្រោយពេលកិច្ចព្រមព្រៀងចូលជាធរមានភ្លាមៗ ឬ តាមអត្រាផ្សេងទៀតជា បន្តបន្ទាប់ យោងតាមកថាខ័ណ្ឌ កខាងលើ ។ អត្រាដែលកំណត់នៅថ្ងៃទី ៣០ មិថុនា នៃឆ្នាំនីមួយៗ ត្រូវបានចាប់អនុវត្តពីកាលបរិច្ឆេទទូទាត់បន្ទាប់នៃឆ្នាំនោះដូចដែលបានបញ្ជាក់ក្នុងផ្នែក ២.០៦ នៃកិច្ចព្រមព្រៀងនេះ។

(គ): អ្នកខ្ចីត្រូវទូទាត់សងបន្ទុកកិច្ចសន្យា (i) តាមទីកន្លែងដែលសមាគមសំណូមពរ (ii) ដោយគ្មានព្រំដែនលើប្រភេទចាប់បង្ខំណាមួយ (iii) ហើយដោយរូបិយប័ណ្ណជាក់លាក់ក្នុងកិច្ចព្រមព្រៀងនេះ ដើម្បីគោលបំណងក្នុងផ្នែក ២.០៤ នៃលក្ខខ័ណ្ឌទូទៅទាំងឡាយ ឬ រូបិយប័ណ្ណផ្សេងទៀតដែលយកជាការបាន ឬ ជ្រើសរើសតាមប្រភេទសមស្របតាមខ្លឹមសារដែលបានចែងកងផែកនោះ ។

ផ្នែក ២.០៥ : អ្នកខ្ចី ត្រូវទូទាត់សងនៅសមាគម នូវបន្ទុកសេវាមួយតាមអត្រា ៣ ភាគ ៤ នៃ ១% ក្នុងមួយឆ្នាំលើចំនួនប្រាក់ដើម នៃឥណទានដែលបានដក និង ចំនួនកំពុងប្រព្រឹត្តទៅបន្តបន្ទាប់ ។

ផ្នែក ២.០៦ : បន្ទុកកិច្ចសន្យា និង បន្ទុកសេវា ត្រូវទូទាត់ពីរដងក្នុងមួយឆ្នាំ ពោលគឺនៅថ្ងៃទី ០១ ខែ ឧសភា ម្តង និងនៅថ្ងៃទី ០១ ខែ វិច្ឆិកា ម្តង រៀងរាល់ឆ្នាំ ។

ផ្នែក ២.០៧ : យោងតាមកថាខ័ណ្ឌ «ខ» និង «គ» ខាងក្រោម អ្នកខ្ចីត្រូវទូទាត់សងវិញ ចំពោះប្រាក់ដើម នៃឥណទានពីរដងក្នុងមួយឆ្នាំ នៅថ្ងៃទី ០១ ឧសភា ម្តងនិងថ្ងៃទី ០១ វិច្ឆិកា ម្តងជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៥ ព្រមទាំងបញ្ចប់នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០៣៤ ។ ការទូទាត់តាមលើកនីមួយៗ រួមទាំងចាប់ពីដើមដំបូង ពោលគឺថ្ងៃទី ០១ ឧសភា ឆ្នាំ ២០១៤ ត្រូវជា ១ ភាគរយ លើចំនួនប្រាក់ដើម ។ ហើយក្រោយមកការទូទាត់តាមលើកនីមួយៗ ត្រូវកំណត់ ២ ភាគរយ លើចំនួនប្រាក់ដើម ។

(ខ): ពេលណា (i) ផលិតផលជាតិដុលក្នុងម្នាក់ៗ ដែលកំណត់ដោយសមាគម លើសពីប្រាំពីររយកៅសិប «៧៩០» ដុល្លារអាមេរិក គិតតាមតំលៃស្មើរភាពនាឆ្នាំ ១៩៨៥ សំរាប់ ៥ ឆ្នាំ បន្តបន្ទាប់ ហើយ (ii) ធនាគារចាត់ទុកអ្នកខ្ចី «អ្នកមានលទ្ធភាពសង» សមាគមអាចកែសំរួលលើប្រការទូទាត់តាមដំណាក់ៗ ក្រោមកថាខ័ណ្ឌខាងលើ គឺរូវអោយអ្នកខ្ចីទូទាត់ជាពីរដង លើចំនួនដែលត្រូវទូទាត់តាមលើកនីមួយៗ រហូតដល់ឥណទានទាំងមូល ត្រូវទូទាត់រួចរាល់ ។ បើសិនជាមានសំណូមពរពីអ្នកខ្ចី សមាគមអាចពិនិត្យ កែសំរួលឡើងវិញ លើករណីខ្លះៗ ឬ ទាំងអស់លើចំនួន នៃជំហ៊ានទូទាត់បែបនេះ ការសងការតាមអត្រាប្រចាំឆ្នាំ បានឯកភាពជាមួយសមាគម លើចំនួនប្រាក់ដើម នៃឥណទានដែលបានដក និង ចំនួនកំពុងប្រព្រឹត្តទៅជាបន្តបន្ទាប់ ។ ក្នុងការវិនិច្ឆ័យរបស់សមាគម ការពិនិត្យឡើងវិញ នឹងមិនផ្លាស់ប្តូរកត្តា សំខាន់ៗ ដែលទទួលបានក្រោមការកែសំរួលទូទាត់គួសបញ្ជាក់ខាងលើ ។

(គ): បើសិនជានៅពេលណាមួយ បន្ទាប់ពីមានការកែសំរួលលើលក្ខខ័ណ្ឌ តាមកថាខ័ណ្ឌ «ខ» ខាងលើ និង ក្រោយពេលក្រុមប្រឹក្សាភិបាលធនាគារបានពិចារណា ហើយសមាគមកំណត់ថា បើលក្ខខ័ណ្ឌសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់យ៉ាងខ្លាំងនោះ យោងតាមសំណើរបស់អ្នកខ្ចី ធនាគារអាចកែលំអលក្ខខ័ណ្ឌ

ដើម ក្នុងការសងអនុលោមតាមកម្មវិធីទូទាត់តាមលើកនីមួយៗ នៃកថាខ័ណ្ឌ (គ) ខាងលើ ។

ផ្នែក ២.០៨ : បរិយវត្ថុ នៃសហរដ្ឋអាមេរិក គឺត្រូវបានបញ្ជាក់ សំរាប់គោលបំណងនានានៃ ផ្នែក៤.០២ នៃលក្ខខ័ណ្ឌទូទៅ ។

មាត្រា III

ប្រតិបត្តិគំរោង

ផ្នែក ៣.០១ (ក): អ្នកខ្ចីប្រកាសនូវកិច្ចសន្យារបស់ខ្លួន ចំពោះគោលដៅ នៃគំរោងនេះ ឆ្លងតាម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ភ្នាក់ងារអនុវត្តគំរោងជាមួយនឹងការយក ចិត្តទុកដាក់ផ្តល់ផលប្រយោជន៍រៀបចំ សមស្របលើការងាររដ្ឋបាលសេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស សំភារៈ សៅវាសាធារណៈ ដើម្បីឆ្លើយតបបានទាន់ ពេលវេលា ។

(ខ): អ្នកខ្ចី ត្រូវអនុវត្តសមស្របតាមផែនការអនុវត្តគំរោង ដូចបានចែងក្នុងកម្ម វិធី ៥ នៃកិច្ចព្រមព្រៀងដោយគ្មានកំណត់ព្រំដែន អនុលោមតាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ លើកលែងតែមានការព្រមព្រៀងរវាងអ្នកខ្ចី និងសមាគម ។

ផ្នែក ៣.០២ : អនុលោមតាមសេចក្តីដែលបានចែងក្នុងមាត្រា ៩ នៃលក្ខខ័ណ្ឌទូទៅ អ្នកខ្ចី ត្រូវ :

(ក. រៀបចំ និង ផ្តត់ផ្គង់ដល់សមាគមអោយបានមុន ៦ ខែបន្ទាប់ពីកាលបរិច្ឆេទ បន្ទាប់ ណាមួយទៀតដែលបានឯកភាពគ្នារវាងអ្នកខ្ចី និង សមាគមនូវផែន ការចំណុចដៅជាលំអិតតាមសំណើ សមហេតុផលរបស់សមាគម សំរាប់កិច្ច ប្រតិបត្តិគំរោងទៅអនាគត ។

(ខ): បង្កលក្ខណៈដល់សមាគមនូវឱកាសសមស្របមួយក្នុងការប្តូរទស្សនៈជាមួយអ្នក ខ្ចី លើផែនការខាងលើ

(គ): អនុវត្តផែនការដោយត្រឹមត្រូវ និងមានប្រសិទ្ធភាពយោងទៅតាមបទពិសោធន៍ ជាក់ស្តែង និង ស្របតាមគោលបំណងរបស់ធនាគារ

ផ្នែក៣.០៣(ក): ជានិច្ចជាកាល រហូតដល់ចុងបញ្ចប់នៃគំរោង អ្នកខ្ចីត្រូវរក្សា អគគ ក្នុងក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងកំលាំង មនុស្ស និង សំភារៈចាំបាច់ ធ្វើអោយប្រាកដថា អគគ ត្រូវបានដឹកនាំដោយ

អ្នកសិរបសិរ្សិលគំរោង ដោយមានសមត្ថភាព និង ទទួលយកបានដោយសមាគម ហើយមន្ត្រីដែលបំពេញការងារទៀតសោត ត្រូវមានសមត្ថភាពជាមួយបរិមាណសមរម្យហើយផ្តល់បានឆាប់រហ័ស នូវរាល់មូលនិធិគ្រឿងសំភារៈសេវាផ្សេងៗទៀត ដែលតំរូវការដើម្បីអោយ អគគ បំពេញភារកិច្ច មុខងារក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

(ខ): អគគ ជាបឋមត្រូវតែយកចិត្តទុកដាក់ធ្ងន់លើការងារគ្រប់គ្រងជាទូទៅ រដ្ឋបាល កិច្ចសិរបសិរ្សិលអនុវត្តគំរោងរួមទាំងការផ្គត់ផ្គង់រាល់ទំនិញសេវាកម្មការងារ ។ល។ តាមសំណូមពរ ។

(គ): អ្នកខ្ចីត្រូវបង្កលក្ខណៈដល់ អគគ ក្នុងការរៀបចំ និង ផ្គត់ផ្គង់ដល់សមាគមលើការសើរើពិនិត្យអោយបានមុនថ្ងៃទី ៣០ មិថុនា និង ៣១ ធ្នូ ក្នុងឆ្នាំសារពើពន្ធនីមួយៗ លើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីដំណើរការអនុវត្តន៍គំរោងរបស់អ្នកខ្ចី ព្រមទាំងរាល់ការចំណាយទាក់ទងទៅនឹងគំរោងនេះ ។

ផ្នែក ៣.០៤ : សំរាប់គោលបំណងនៃការអនុវត្តន៍គ្រង់ភាគ ក.១ នៃគំរោង អ្នកខ្ចីត្រូវ :

(ក): តែងតាំងមន្ត្រីទាំងឡាយដែលត្រូវរួមសហការ លើលក្ខខ័ណ្ឌទាំងឡាយដែលព្រមព្រៀងគ្នា ដោយពេញចិត្តរបស់សមាគម ក្នុងកិច្ចសហការ នៅពេលអ្នកជំនួយការមកដល់ ឬការប្រគល់នូវប្រព័ន្ធគ្រប់គ្រងពត៌មានវិទ្យា និងធ្វើអោយប្រាកដថា ភ្នាក់ងារគំរោងដែលអនុវត្តនូវមុខសញ្ញាផែនការការងារខ្លួនគឺយោងលើកម្មវិធី ការងារឆ្នាំ នៃផែនការក្រោមផែនការអនុវត្តន៍គំរោង និងបន្ទាប់មកទៀតត្រូវសើរើពិនិត្យ និង តាមដានជាប់លើផែនការនេះ ដោយពិគ្រោះយោបល់ជាមួយសមាគម អោយបានមុនថ្ងៃទី ៣១ មិថុនា រៀងរាល់ឆ្នាំសារពើពន្ធ ដោយចាប់ផ្តើមពីពេលបញ្ចប់ឆ្នាំសារពើពន្ធនាថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៥ ។

ផ្នែក ៣.០៥ : សំរាប់គោលបំណងនៃការអនុវត្តគ្រង់ភាគ ខ នៃគំរោងអ្នកខ្ចីត្រូវ :(ក) បង្កើត និង រក្សារហូតដល់ពេលបញ្ចប់ នៃគំរោងនូវអង្គភាពកែទម្រង់ច្បាប់ (អកច ក្រោមនិវាទ កច) អោយបានមុនថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩៥ ។ ការបង្កើតអង្គភាពនេះ ត្រូវសមស្របទៅនឹងប្រការទាំងឡាយ និង ប្រភពធនធានដែលសមាគមពេញចិត្ត ត្រូវបានដឹកនាំជាប្រចាំដោយទីប្រឹក្សាអ្នកច្បាប់ ដែលពោរពេញទៅដោយបទពិសោធន៍ និង បានទទួលជំនួយគាំទ្រយ៉ាងមុតមាំពីមន្ត្រី

ស្នាត់ជំនាញខាងច្បាប់មួយចំនួនសមស្រប (ខ) រៀបចំ អនុម័តរកាយការណ៍ជាផ្លូវការ ស្តីពីច្បាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបទពញ្ញាផ្សេងៗ ដែលត្រូវផ្សព្វផ្សាយក្នុងកំឡុងពេលពីឆ្នាំ ១៩៩៥ ដល់ ១៩៩៨ សំរាប់អភិវឌ្ឍន៍នូវមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ សកម្មភាពវិស័យឯកជន ។

ផ្នែក ៣.០៦ : ដោយគោរពទៅតាមកម្មវិធីសិក្សា បំពាក់បំប៉នដែលត្រូវអនុវត្តក្រោម ភាគ គ នៃគំរោងអ្នកខ្ចីត្រូវផ្តល់ដល់សមាគម ក្នុងការអនុមតិមុនគេ :(ក) ប្រការជាមូលដ្ឋានទាំងឡាយក្នុងការអនុវត្ត ផ្តល់ហិរញ្ញប្បទាន និង ត្រួតពិនិត្យតាមដានការសិក្សាខាងលើ និង (ខ) ប្រការជាមូលដ្ឋាន នៃកម្មវិធីបណ្តុលបណ្តាលទាំងឡាយព្រមទាំងកម្មវិធីសំរាប់ការអនុវត្តន៍របស់វា និង លក្ខណៈសម្បត្តិជ្រើសរើសមុខសញ្ញាអោយចូលក្នុងវគ្គបណ្តុះបណ្តាលនេះ ។

ផ្នែក ៣.០៧ : គ្មានកំណត់ព្រំដែន អនុលោមតាមខ្លឹមសារទាំងឡាយ ដែលបានចែងក្នុងលក្ខខ័ណ្ឌទូទៅ នៃកិច្ចព្រមព្រៀង :(ក) លើមូលដ្ឋាននៃប្រការទាំងឡាយដែលសមាគមទទួលយល់ព្រម អោយបានមុនថ្ងៃទី ៣០ មិថុនា ១៩៩៧ អ្នកខ្ចីត្រូវដឹកនាំវគ្គយល់ដឹង ស្តីពីការសើរើពិនិត្យឡើងវិញ លើលទ្ធផលនៃការអនុវត្តន៍គំរោងរបស់អ្នកខ្ចី និង (ខ) ចាប់អារម្មណ៍ដល់យោបល់ណែនាំរបស់សមាគមក្រោយការសើរើពិនិត្យ អ្នកខ្ចីត្រូវតែអនុវត្តអោយបានត្រឹមត្រូវ និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងចាត់វិធានការចាំបាច់ ដើម្បីឈានទៅសំរេចអោយបានជោគជ័យទាំងស្រុង ចំពោះគោលដៅនៃគំរោង ។

ផ្នែក ៣.០៨ : លើកលែងតែមានការព្រមព្រៀងដោយឡែកពីសមាគម ការផ្គត់ផ្គង់ទំនិញ ការងារសេវាសំរាប់គំរោង ហើយត្រូវបានផ្តល់ហិរញ្ញប្បទានចេញឥណទាន ត្រូវគោរពតាមខ្លឹមសារទាំងឡាយដែលបានចែងក្នុងកម្មវិធី ៣ នៃកិច្ចព្រមព្រៀង។

មាត្រា IV

បទបញ្ញត្តិហិរញ្ញវត្ថុ

ផ្នែក ៤.០១ (ក): អ្នកខ្ចីត្រូវរក្សា ឬ បង្កអោយមានស្ថេរភាព បញ្ជីការអោយបានច្បាស់លាស់ និងឆ្លុះបញ្ចាំងអោយបានត្រឹមត្រូវ ជាមួយប្រតិបត្តិការជាក់ស្តែងទាំងចំណាយ និងចំណូល ដោយគោរពតាមគំរោងរបស់នាយកដ្ឋាន ភ្នាក់ងារដែលទទួលខុសត្រូវក្នុងការអនុវត្តន៍គំរោង ឬ ផ្នែកណាមួយ នៃគំរោង

(ខ): អ្នកខ្ចីត្រូវ (i) កត់ត្រា និង បញ្ជីការផ្នែក តាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ ក្នុងនោះក៏ត្រូវធ្វើដូចគ្នាដែរ ចំពោះគណនីពិសេសក្នុងឆ្នាំសារពើព័ន្ធនីមួយៗ យោលទៅតាមគោលការណ៍ជំរះបញ្ជីសមស្រប ធ្វើឡើងដោយក្រុមជំរះបញ្ជី ដែលមានការយល់ព្រមដោយសមាគមផង ។ (ii) ផ្តល់អោយសមាគម អោយបានឆាប់រហ័ស ធ្វើយ៉ាងណាកុំអោយលើសពី ៦ ខែ បន្ទាប់ពីបញ្ចប់ឆ្នាំនីមួយៗ នូវឯកសារបញ្ជាក់របាយការណ៍ របស់អ្នកជំរះបញ្ជី ត្រូវលំអិតតាមសំណូមពរសមហេតុផលរបស់សមាគម ។

(iii) ផ្តល់ដល់សមាគមនូវពត៌មានទាក់ទងទៅនឹងកិច្ចបញ្ជីកា និង ការជំរះបញ្ជី គណនីនានាតាមសំណើរបស់សមាគម ។

(គ): ចំពោះរាល់ការចំណាយដែលដកពីគណនីឥណទានគឺត្រូវបានធ្វើលើមូលដ្ឋាននៃសេចក្តីប្រកាស អ្នកខ្ចីត្រូវ : (i) រក្សាបង្គលក្ខណៈ រក្សាស្មេរភាពអនុលោមតាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ ដើម្បីកត់ត្រា និង ឆ្លុះបញ្ចាំងរាល់ការចំណាយបែបនេះ ។ (ii) រក្សាទុកបន្តរហូតដល់យ៉ាងហោចណាស់មួយឆ្នាំសារពើពន្ធ ពីការដកប្រាក់លើកមុនពីគណនីឥណទាន ឬ ការទូទាត់ ត្រូវបានធ្វើអោយ អស់ពីគណនីពិសេស ការកត់ត្រាទាំងអស់នូវកិច្ចសន្យាបញ្ជាទិញ វិក័យប័ត្រ បង្កាន់ដៃ និង ឯកសារផ្សេងទៀត ជាសក្ខីប័ត្រចំណាយ ។ (iii) ជួយធ្វើជា តំណាងអោយសមាគម ដើម្បីត្រួតពិនិត្យលើការកត់ត្រាទាំងអស់នេះ ។ (iv) ធានាការកត់ត្រាគណនីទាំងនេះ ត្រូវបញ្ចូលទាំងការជំរះបញ្ជីក្នុងឆ្នាំ អនុលោមតាមកថាខ័ណ្ឌ «ខ» នៃផ្នែកនេះ ព្រមទាំងរបាយការណ៍ នៃការជំរះបញ្ជីនេះ ត្រូវវែកញែកយោបល់របស់អ្នកជំរះបញ្ជីខាងលើ ចំណែកឯរបាយការណ៍ ចំណាយដែលដាក់ជូនក្នុងកំឡុងឆ្នាំសារពើពន្ធ រួមជាមួយនឹងទំរង់ការ និង ការ ត្រួតពិនិត្យផ្ទៃក្នុងទាក់ទង និងការរៀបចំរបស់ខ្លួនអាចទុកចិត្តនិងគាំទ្រដល់ការដកប្រាក់ចេញ ។

មាត្រា V

កាលបរិច្ឆេទជាធរមាន និង កាលកំណត់បញ្ចប់

ផ្នែក ៥.០១ : រយៈពេល ១២០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងត្រូវបានបញ្ជាក់ច្បាស់លាស់ចំពោះគោលដៅ នៃផ្នែក ១២.០៤ នៃលក្ខខ័ណ្ឌទូទៅ ។

ផ្នែក ៥.០២ : ភារកិច្ចរបស់អ្នកខ្ចី ផ្អែកតាមមាត្រា ៣ និង ៤ នៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ឈប់នៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងបានបញ្ចប់ឬមួយនៅកាលបរិច្ឆេទម្ភៃ (២០)ឆ្នាំ ក្រោយកាលបរិច្ឆេទកិច្ចព្រមព្រៀងនេះ ដែលជាកាលកំណត់ចាប់បំផុត ។

មាត្រា VI

តំណាង អ្នកខ្ចី អាស័យដ្ឋាន

ផ្នែក ៦.០១ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានជ្រើសរើសជាតំណាងអ្នកខ្ចី សំរាប់គោលបំណងនៃផ្នែក ១១.០៣ នៃលក្ខខ័ណ្ឌទូទៅ ។

ផ្នែក ៦.០២ : អាស័យដ្ឋានខាងក្រោមត្រូវបានបញ្ជាក់ច្បាស់សំរាប់គោលបំណងផ្នែក ១១.០១ នៃលក្ខខ័ណ្ឌទូទៅ ។

ចំពោះភាគីអ្នកខ្ចី : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

តេឡិច :(៥៨៣)១៧៧០១០១ CMPP

ចំពោះសមាគម : សមាគមអភិវឌ្ឍន៍អន្តរជាតិ

វិថីលេខ : ១៨១៨ H,N.W
វ៉ាស៊ីនតោន, ឌីស៊ី . ២០៤៣៣
សហរដ្ឋអាមេរិក

	Telex :
cable Address INDEVAS វ៉ាស៊ីនតោន, ឌីស៊ី	: ២៤៨៤២៣(RCA), ៨២៩៨៧ (FTCC), ៦៤១៤៥ (WUI)or ១៩៧៦៨៨ (TRT).

ដើម្បីជាសក្ខីភាពភាគីទាំងពីរ ដែលកំពុងអនុវត្តតាមរយៈតំណាងដែលបានទទួលការអនុញ្ញាតសិទ្ធិត្រឹមត្រូវរបស់ភាគីនីមួយៗ បានបង្កលក្ខណៈអោយកិច្ចព្រមព្រៀងគណនាន បានចុះ

ហត្ថលេខារៀងៗ ខ្លួននៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃ. ខែ. ឆ្នាំ ដែលបានចែង ពីដំបូងខាងលើ ។

ព្រះរាជាណាចក្រកម្ពុជា
ដោយ តំណាងមានសមត្ថកិច្ច គាត ឈន់

សមាគមអភិវឌ្ឍន៍អន្តរជាតិ
ដោយ តំណាងមានសមត្ថកិច្ច អារណូ ហ្វ៊ីណា

* * *

កម្មវិធី១

ការដកប្រាក់ឥណទាន

១–តារាងខាងក្រោមចែងអំពីប្រភេទមុខចំណាយដែលត្រូវបានហិរញ្ញប្បទានពីទឹកប្រាក់នៃឥណទាន ការផ្តល់ចំនួនប្រាក់ នៃឥណទានសំរាប់ប្រភេទមុខចំណាយនីមួយៗ និង ភាគរយនៃមុខចំណាយ ដែលត្រូវបានហិរញ្ញប្បទានក្នុងប្រភេទនីមួយៗ

	ប្រភេទ	ចំនួនប្រាក់ឥណទាន ត្រូវផ្តល់ សមមូលជា SDR	ភាគរយនៃចំណាយ ត្រូវហិរញ្ញប្បទាន
(១)	សាងសង់ ក្នុងផ្នែកក (២) នៃគំរោង	៥២២.០០០	៩០%
(២)	ទំនិញ	៨៤៧.០០០	១០០%នៃចំណាយក្រៅប្រទេស ១០០%នៃចំណាយក្នុងស្រុក (បរិយាទានផលិតកម្ម) និង ៩០% ចំណាយក្នុងប្រទេសសំរាប់ទំនិញផ្សេងៗទៀតក្នុងស្រុក។
(៣)	សេវាពិគ្រោះ	៧.៩៥៣.០០០	១០០%
(៤)	បណ្តុះបណ្តាល	៩៧៨.០០០	១០០%

(៥) ការសិក្សាស្រាវជ្រាវ ៧៥២.០០០ ១០០%

(៦) ត្រៀមបំរុង ៥១៨.០០០

សរុប ១១.៦០០.០០០

២–សំរាប់គោលបំណងនៃកម្មវិធី ១ :

ពាក្យ «ចំណាយក្រៅប្រទេស » មានន័យថាចំណាយជារូបិយវត្ថុរបស់ប្រទេសណាមួយក្រៅពីប្រទេសអ្នកខ្ចីសំរាប់ទំនិញ រឺសេវាដែលផ្គត់ផ្គង់ពីទឹកដីនៃប្រទេសក្រៅ ក្រៅពីប្រទេសអ្នកខ្ចី និង

ពាក្យ «ចំណាយក្នុងប្រទេស» មានន័យថា ចំណាយជារូបិយវត្ថុ របស់ប្រទេសអ្នកខ្ចី សំរាប់ទំនិញ ឬ សេវា ដែលផ្គត់ផ្គង់ពីទឹកដីនៃប្រទេសអ្នកខ្ចី ។

៣–ដោយបដិបញ្ញត្តិចំពោះកថាខ័ណ្ឌ ១ ខាងលើការដកប្រាក់សំរាប់ទូទាត់ចំណាយ ពុំអាចប្រព្រឹត្តទៅបានមុនកាលបរិច្ឆេទ នៃកិច្ចព្រមព្រៀងនេះទេ ។

៤–សមាគមអាចតំរូវអោយដកប្រាក់ពីគណនីឥណទាន ដែលធ្វើឡើងដោយផ្អែកលើមូលដ្ឋានបញ្ជីសំរង់ចំណាយតាមកិច្ចសន្យាទាំងឡាយ :

តំលៃការងារមិនហួសសមមូលមួយរយពាន់ដុល្លារ (១០០.០០០)

ទំនិញមិនហួសសមមូល ហាសិបពាន់ដុល្លារ (៥០.០០០)

ក្រុមហ៊ុនពិគ្រោះមិនហួសសមមូលមួយរយពាន់ដុល្លារ (១០០.០០០០)

អ្នកពិគ្រោះជាបុគ្គលមិនហួសសមមូលហាសិបពាន់ដុល្លារ (៥០.០០០) និង

គ្រប់តំលៃបណ្តុះបណ្តាលទាំងអស់ក្រោមកាលកំណត់ និង ល័ក្ខខ័ណ្ឌកាលណាសមាគមបញ្ជាក់សេចក្តី ប្រកាសជូនអ្នកខ្ចី ។

កម្មវិធីទី២

ពិពណ៌នាអំពីគំរោងការ

គោលដៅនៃគំរោងការ គឺជួយអោយអ្នកខ្ចីបង្កើត និងអនុវត្តការកែទំរង់ស្ថាប័ន ដើម្បី (i) កែលំអការងារគ្រប់គ្រងហិរញ្ញវត្ថុផ្នែកសាធារណៈ និង (ii) បង្កើតបរិដ្ឋាន នីតិសម្បទាមួយសំរាប់អភិវឌ្ឍន៍ឯកជន ។

គំរោងការរួមមានផ្នែកដូចតទៅ ដែលអាចកែប្រែបាន កាលណាអ្នកខ្ចី និង សមាគមយល់ព្រមជាមួយគ្នាថា នឹងឈានដល់គោលដៅទាំងនោះជាបន្ទាន់ :

ផ្នែក ក: ការងារគ្រប់គ្រងផ្នែកសាធារណៈ

១–ផ្តត់ផ្គង់ជំនួយការបច្ចេកទេស ដើម្បីជួយជ្រោមជ្រែង ដល់អ្នកខ្ចី ក្នុងការអនុវត្តនីតិវិធីកែទំរង់ការងារគ្រប់គ្រង ផ្នែកសាធារណៈដោយ:

(ក) ពង្រឹងសមត្ថភាព ស្ថាប័នរបស់អ្នកខ្ចី តាមរយៈការត្រួតពិនិត្យចំណាយសាធារណៈ ដោយពង្រីកសមត្ថភាពចាំបាច់ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងរៀបចំថវិកាជាតិ និងខេត្ត–ក្រុងប្រចាំឆ្នាំ (ii) សមាសង្សកម្ម នីតិវិធីគ្រប់គ្រងថវិកា ចូលក្នុងវដ្តនៃផែនការកម្មវិធីថវិកា (iii) កែលំអប្រព័ន្ធអនុវត្ត ថវិកា ធ្វើអធិការកិច្ច និង ត្រួតពិនិត្យ (iv) អភិវឌ្ឍន៍ប្រព័ន្ធមួយសំរាប់អធិការកិច្ច ប្រតិបត្តិការរតនាគារ និង រៀបចំបញ្ជីវិភាគប្រចាំខែ (v) បង្កើតប្រព័ន្ធល្បាករណ៍ប្រចាំខែស្តីពីចំណូលចំណាយរតនៈវត្ថុ (vi) បង្កើតចេញវិធានរដ្ឋបាលនិងគណនេយ្យ ព្រមទាំងនីតិវិធីប្រមូលចំណូល និងកិច្ចប្រតិបត្តិការ ចំណាយ(vii) ពង្រីកនីតិក្របខ័ណ្ឌ និង បទបញ្ញាចំពោះគណនេយ្យសាធារណៈ (viii) កែលំអប្រមូលកិច្ចប្រតិបត្តិការគណនេយ្យ នៅកំរិតមួយនៅតាមខេត្ត–ក្រុង និង (ix) បង្កើតប្រព័ន្ធគណនេយ្យ មួយ សំរាប់កិច្ចប្រតិបត្តិការរូបិយវត្ថុបរទេស ។

(ខ) ពង្រឹងសមត្ថភាពស្ថាប័ន របស់អ្នកខ្ចីដើម្បីធ្វើផែនការកម្មវិធី និងគ្រប់គ្រងវិនិយោគសាធារណៈដោយ (i) បង្កើតអង្គភាពថវិកា វិនិយោគសាធារណៈ ក្រោមនិវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ii) អភិវឌ្ឍន៍ ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ តាមបែបពតិមានវិទ្យានៅអង្គភាពដែលបាន និយាយខាងលើនេះ (iii) បង្កើតនីតិវិធី និង បទបញ្ញាសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ និងត្រួត ពិនិត្យគំរោងការ (iv) បង្កើតសមត្ថភាពជាយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិង (v) អភិវឌ្ឍន៍ សមត្ថភាពវិភាគម៉ាក្រូសេដ្ឋកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(គ) ពង្រឹងសមត្ថភាពស្ថាប័នរបស់អ្នកខ្ចី សំរាប់គ្រប់គ្រងបំណុលក្រៅប្រទេសដោយ: (i) ពង្រឹងនីតិក្របខ័ណ្ឌ និង ភាពចាំបាច់នៃស្ថាប័ន និង សំរបសំរួលអង្គការចាត់តាំង និងនីតិវិធីរាយការណ៍ ចំពោះការងារគ្រប់គ្រងបំណុលក្រៅប្រទេស និងរបបរាយការណ៍ និង (ii) បង្កើតអង្គភាពគ្រប់គ្រងបំណុលសាធារណៈក្រោមនិវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(ឃ) ពង្រឹង សមត្ថភាពស្ថាប័ន អ្នកខ្ចីសំរាប់កែ ទំរង់ផ្នែកគ្រប់គ្រងមុខងារសាធារណៈ ដោយតាក់តែងយុទ្ធសាស្ត្រត្រៀមបំរុង និង បង្កើតជំរើសដែលទាក់ទងជាមួយដើម្បីរៀបចំឡើង

វិញ នូវមុខងារសាធារណៈរបស់អ្នកខ្ចី និង បង្កើនប្រសិទ្ធភាពរបស់វាទាំងនៅក្នុងសហគ្រាសសាធារណៈទៀតផង ។

២–សាងសង់ និងបំពាក់បរិក្ខារ មជ្ឈមណ្ឌលបណ្តុះបណ្តាល វិក្រឹតការ និងសុក្រឹតការជំនាញបច្ចេកទេស ចំនួនប្រហែលប្រាំមួយរយអ្នក (៦០០) ក្នុងមួយឆ្នាំខាងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៣–ផ្គត់ផ្គង់ ម៉ាស៊ីនកុំព្យូទ័រ និងឧបករណ៍យន្ត និងបរិក្ខារស្វ័យប្រវត្តិ បំពេញសំភារៈ និងមូលដ្ឋានប្រមូលទិន្នន័យ សមស្របទៅនឹងសកម្មភាពសំរាប់កឋាខ័ណ្ឌ ១ខាងលើ ។

ផ្នែក ខ: ជំនួយការ បច្ចេកទេសគតិយុត្តដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

១–អនុវត្តការសិក្សានីតិព្យាករណ៍លើការកំណត់ (ក) វិធីសាស្ត្រ និង បទបញ្ញត្តិអភិវឌ្ឍន៍បច្ចុប្បន្ននៃច្បាប់និងបទបញ្ញាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង(ខ)កំរិតសមត្ថភាពនៃច្បាប់ និង បទបញ្ញាផ្សេងៗ នៃ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុព្រមទាំងបទបញ្ញាទាំងឡាយដែលកំពុងអនុវត្តជាធរមានទៅទឹកដីរបស់អ្នកខ្ចី ។

២–ធ្វើការប៉ាន់ស្មាន តំរូវការបណ្តុះបណ្តាល ពេញលក្ខណៈច្បាប់ ដើម្បីកំណត់អោយបាន នូវតំរូវការស្របច្បាប់ ជាអាទិភាពរបស់អ្នកខ្ចីព្រមទាំងធ្វើសំណូមពរកម្មវិធី សមស្របចាំបាច់ដល់តំរូវការទាំងនេះ ។

៣–ផ្អែកតាមការរកឃើញ និងអនុសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងប៉ាន់ស្មានទៅក្នុងកឋា ខ័ណ្ឌ១ និង ២ ដូចបានចែងខាងលើ និងស្ថានភាពផ្លូវការរបស់អ្នកខ្ចីស្តីពីច្បាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាទិភាពដោយអនុលោមតាមផ្នែក ៣,០៥ (ខ)នៃកិច្ចព្រមព្រៀងនេះ ត្រូវរៀបចំ និង អនុវត្តកម្មវិធី ផែនការម្ចាស់ការ ដើម្បីព្រាងនិងត្រួតពិនិត្យច្បាប់ និងបទបញ្ញាជាអាទិភាព នៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង(ខ)រៀបចំបើក សិក្ខាសាលាបណ្តុះបណ្តាលលក្ខណៈច្បាប់សំរាប់ចៅក្រម,យុត្តិវិទូ មន្ត្រីរាជការ ព្រមទាំងវិជ្ជាជីវៈផ្សេងៗ ទៀតរបស់អ្នកខ្ចី ។

៤–បង្កើតប្រព័ន្ធស្វ័យប្រវត្តិ ដើម្បីបោះពុម្ពលើមូលដ្ឋានទៀងទាត់ (ក)រាជកិច្ចរបស់អ្នកខ្ចីជាភាសាខ្មែរបារាំង និងអង់គ្លេស (ខ)សេចក្តីសំរេចរបស់តុលាការកំពូលរបស់អ្នកខ្ចី និងសេចក្តីទាំងឡាយ ស្តីពីលិទ្ធិ និងនីតិសាស្ត្រ និង (គ)សៀវភៅតម្កល់ម៉ាកសញ្ញាដោយ ពណ៌

៥–ផ្គត់ផ្គង់ម៉ាស៊ីនកុំព្យូទ័រកម្មវិធី បរិក្ខារស្វ័យប្រវត្តិ សំភារៈមូលដ្ឋានប្រមូលទិន្នន័យ សមស្របតាមសកម្មភាព កឋាខ័ណ្ឌ ១,២,៣ និង ៤ ដូចបានចែងខាងលើ ។

ផ្នែក គៈ ពង្រឹងបណ្តុះបណ្តាលសិក្សាស្រាវជ្រាវ និងស្ថាប័ន

១-អនុវត្តកម្មវិធីបណ្តុះបណ្តាល (ទាំងក្នុងស្រុកនិងក្រៅស្រុក) ការងារប្រតិបត្តិ សមស្របតាមសកម្មភាពដែលបានចែងក្នុងផ្នែក ក និង ខ ខាងលើ ។

២-ផ្តល់ផ្តល់សេវានីតិប្រឹក្សាដល់ កថ, គណ, ពណ, យធ និង គអក

៣-អនុវត្ត (i) សិក្សាស្រាវជ្រាវលើកិច្ចអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ របស់អ្នកខ្ចី និង (ii) សិក្សាគសំរាំងការសិក្សា គោលនយោបាយផ្នែកតាមវិស័យសេដ្ឋកិច្ចរបស់អ្នកខ្ចី ដូចៈ វាក្យខ័ណ្ឌៈ កសិកម្ម ពាណិជ្ជកម្ម អប់រំ ថាមពល បរិដ្ឋាន សុខាភិបាល ឧស្សាហកម្ម ស្ថិតិ និង ភាពដែលអាចធ្វើទៅបានតាមកម្មវិធីអាស្យាណា នៃការផ្ទេរបេឡាទៅខេត្តក្រុង ។

៤-ផ្តល់ផ្តល់ជំនួយសំភារៈបច្ចេកទេស និងបណ្តុះបណ្តាលដល់ អគត ក្នុងកិច្ចអនុវត្តន៍ការងារគ្រប់គ្រងគំរោងការ សំរបសំរួល អនុវត្ត ត្រួតពិនិត្យ និងការទទួលខុសត្រូវខាងផ្នែកដេញថ្លៃ ។

៥-ផ្តល់ផ្តល់សំភារៈបរិក្ខារួមមាន មាស៊ីនកុំព្យូទ័រ សំភារៈការិយាល័យ បណ្តុះបណ្តាលសមស្របតាមសកម្មភាពដែលបាន កំណត់នៅកថាខ័ណ្ឌ ១.២.៣ និង ៤ខាងលើ ។

ឧបសម្ព័ន្ធ នៃកម្មវិធី ២

ភ្នាក់ងារស្ថាប័នរដ្ឋ របស់អ្នកខ្ចី ដែលបានរាយនាមដូចខាងក្រោម ជាអ្នកទទួលខុសត្រូវក្នុងការជួយជ្រោមជ្រែង រួមចំណែកជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការអនុវត្តគំរោងការ ។

ផ្នែកនៃគំរោងការ	**ស្ថាប័ន / ភ្នាក់ងារ**
ផ្នែក ក(១)(ក)	សហវ
ផ្នែក ក(១)(ខ)	សហវ/គអក
ផ្នែក ក(១)(គ)	សហវ
ផ្នែក ក(១)(ឃ)	គណ / គអក
ផ្នែក ក(២)	សហវ
ផ្នែក ក(៣)	អគត
ផ្នែក ខ(១)	គអក/កថ/ពណ/យធ
ផ្នែក ខ(២)	គអក/កថ/គណ/យធ
ផ្នែក ខ(៣)	គណ/កថ/យធ
ផ្នែក ខ(៤)	គណ/ពណ/យធ

ផ្នែក	ខ(៥)	អគត
ផ្នែក	គ(១)	អគត
ផ្នែក	គ(២)	កប/គណ/ពណ/យធ
ផ្នែក	គ(៣)	សហវ
ផ្នែក	គ(៤)	អគត
ផ្នែក	គ(៥)	អគត

កម្មវិធី ៣

កិច្ចការដេញថ្លៃ និងអ្នកពិគ្រោះ

ផ្នែក I: ដេញថ្លៃទំនិញ និងពលកម្ម

ភាគ ក : ដេញថ្លៃតាមការប្រជែងអន្តរជាតិ

១–លើកលែងករណីដែលបានចែងក្នុងភាគ គ ទំនិញទាំងឡាយត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យា ត្រឹមត្រូវតាមកម្មវិធីដែលបានចែងនៅក្នុងផ្នែក I និង II នៃការណែនាំដេញថ្លៃ ខ្ចីបុល «របស់ធនាគារ អន្តរជាតិដើម្បីនីតិសម្បទា និងអភិវឌ្ឍន៍ » និង ឥណទានរបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ (Guidelines for Procurement under IBRD and IDA Credits) ដែលបានបោះផ្សាយដោយ ធនាគារនៅខែ ឧសភា ឆ្នាំ ១៩៩២ «ការណែនាំ » ព្រមទាំងសម ស្របតាមនីតិវិធីលំអិតដូច តទៅ :

(ក) កាលណាកិច្ចសន្យាមានការយឺតយ៉ាវ ហួសរយៈពេលសុពលភាព នៃការដេញថ្លៃដែលបានកំណត់ពីដើមទី នោះរយៈពេលនេះអាចត្រូវបានពន្យារមួយដង សមស្រប និង អនុលោមតាមបទ បញ្ញត្តិ កថាខ័ណ្ឌ ២,៥៩ នៃ «ការណែនាំ» នូវចំនួនពេល អប្បបរមាមួយសំរាប់បំពេញការវាយតំលៃ ប្រកាសយល់ព្រមជាចាំបាច់ ហើយនិងចុះកិច្ចសន្យា ។ រយៈពេលសុពលភាពនៃការដេញថ្លៃ អាចត្រូវបានពន្យារពេលជាលើកទី២ ក្នុងករណីដែលឯកសារដេញថ្លៃ ឬ ការទាមទារពន្យារពេលផ្តល់នូវការកែតំរូវមួយយ៉ាងសមស្របអំពីថ្លៃផ្គត់ផ្គង់ ឆ្លុះបញ្ចាំង ការប្រែប្រួលនៃបរិយាកាសលទ្ធកម្មរបស់កិច្ចសន្យាក្នុងរយៈពេល នៃការពន្យារពេល ។ ការបង្កើនថ្លៃផ្គត់ផ្គង់ កត់ត្រាចូលក្នុងគណនីនៅតំណាក់វាយតំលៃឡើយ។ ចំពោះកិច្ចសន្យានីមួយៗដែលបានឆ្លងយោបល់ សមាគមត្រួតពិនិត្យជាមុន សមស្រប តាមបញ្ញត្តិភាគ ឃ ១ នៃផ្នែកនេះ ការយល់ព្រមជាមុនរបស់សមាគមទាមទារ: (i) ការពន្យារពេល

លើកទី១ នៃរយៈពេលសុពលភាពនៃការដេញថ្លៃ បើរយៈពេលពន្យារនេះ ហួសចំនួន ៦០ ថ្ងៃ និង(ii) ការពន្យាពេលលើកក្រោយ នៃរយៈពេលសុពលភាពនៃការដេញថ្លៃ ។

(ខ) ក្នុងការដេញថ្លៃទំនិញទៅតាមភាគ ក នេះអ្នកខ្ចីត្រូវប្រើប្រ... បញ្ជីគំរូនៃឯកសារដេញថ្លៃ ដែលប្រកាសអោយប្រើដោយធនាគារ អ្នកខ្ចីអាចប្រើប្រាស់ឯកសារ... ថ្លៃផ្សេងៗ ទៀត ដែល អន្តរជាតិ ទទួលស្គាល់ ហើយសមាគមក៏បានយល់ព្រមផង ។

ភាគ ខ : ចំណូលចិត្តទៅលើផលិតករក្នុងស្រុក

១–ក្នុងការដេញថ្លៃ ទំនិញតាមនីតិវិធីដែលបានអធិប្បាយក្នុងភាគ ក១ ខាងលើ ទំនិញកម្មន្តសាល ក្នុងទឹកដីរបស់អ្នកខ្ចី អាចទទួលយល់ព្រមបាន ក្នុងកំរិតចំណូលចិត្តមួយ សមស្របត្រឹមត្រូវតាម បទបញ្ញត្តិកថាខ័ណ្ឌ ២.៥៥ និង ២.៥៦ និងកថាខ័ណ្ឌពី ១ដល់៤ នៃឧបសម្ព័ន្ធ ២នៃ «ការណែនាំ» ។

ភាគ គ: នីតិវិធីដេញថ្លៃផ្សេងៗទៀត

១–ដេញថ្លៃតាមការប្រជែងក្នុងស្រុក :កិច្ចសន្យាសំរាប់ទំនិញ «រួមទាំងយានយន្ត » និងពលកម្ម ដែលមានតំលៃសម្មូល តិចជាងពីររយពាន់ដុល្លារ (២០០.០០០០ ក៏ប៉ុន្តែ ច្រើនជាង ហាសិប ពាន់ដុល្លារ (៥០.០០០) ក្នុងកិច្ចសន្យាមួយរហូតដល់ចំនួនទឹកប្រាក់សរុប សមមូលនឹងប្រាំបួន រយពាន់ ដុល្លារ (៩០០.០០០) អាចត្រូវបានផ្គត់ផ្គង់ដោយកិច្ចសន្យា ផ្អែកតាមប្រកាសដេញថ្លៃ ប្រជែងគ្នាក្នុង ស្រុកទៅតាមនីតិវិធីសមស្របរបស់សមាគម ។

២–ដេញថ្លៃតាមការពិគ្រោះ : កិច្ចសន្យាទំនិញ «រួមទាំងយានយន្ត » និងពលកម្មដែលមាន តំលៃសម្មូលស្មើនឹង ឬ តិចជាងហាសិបពាន់ដុល្លារ (៥០.០០០០) ក្នុងមួយកិច្ចសន្យារហូតដល់ ចំនួនទឹកប្រាក់សរុបសមមូលនឹងប្រាំមួយរយពាន់ដុល្លារ (៦០០.០០០) អាចត្រូវចុះកិច្ចសន្យា ផ្អែកតាមការប្រៀប ធៀបបញ្ជីតំលៃ យ៉ាងហោចណាស់មកពីអ្នកផ្គត់ផ្គង់បី (៣) ដែលអាច ជ្រើសតាំងបានក្រោម «ការណែនាំ» សមស្របតាមនីតិវិធីដែលសមាគមអាចទទួលយល់ព្រម បាន ។

ភាគ ឃ : សេចក្តីសំរេចនៃការដេញថ្លៃ ពិនិត្យដោយសមាគម

១–ពិនិត្យលើការប្រកាសចូលរួមដេញថ្លៃ បញ្ញត្តិ និង កិច្ចសន្យាចុងក្រោយ :

(ក) ចំពោះកិច្ចសន្យានីមួយៗដែលត្រូវបានផ្គត់ផ្គង់តាមបទបញ្ញត្តិនៃភាគ ក–១ ខាងលើនិង ចំពោះកិច្ចសន្យាពីរដំបូង ដែលត្រូវបានផ្គត់ផ្គង់តាមបទបញ្ញត្តិ នៃភាគគ–១និង គ–២ ខាងលើនីតិវិធី ដែលចែងក្នុងកថាខ័ណ្ឌ២ និង ៤ ឧបសម្ព័ន្ធ១ នៃការណែនាំ ត្រូវបាន អនុវត្ត ។ ក្នុងករណីដែលការទូទាត់កិច្ចសន្យាចេញពីគណនីពិសេស នីតិវិធីទាំងនេះត្រូវ

បានផ្លាស់ប្ដូរដើម្បីធានាថា ឯកសារចម្លងត្រឹមត្រូវចំនួនពីរច្បាប់នៃកិច្ចសន្យា ដែលត្រូវផ្ដល់អោយសមាគមសមស្របតាមកថាខ័ណ្ឌ២ (ឃ) ដែល បាននិយាយខាងលើត្រូវផ្ដល់ជូនសមាគមមុននឹងធ្វើការទូទាត់លើកទី១ ពីគណនីពិសេសក្នុងការគោរព ទៅតាមកិច្ចសន្យានេះ ។

(ខ) ចំពោះកិច្ចសន្យានីមួយៗដែលមិនបានគ្រប់គ្រងដោយកថាខ័ណ្ឌ នីតិវិធីដែលបានចែងនៅក្នុងកថាខ័ណ្ឌ៣ និង៤នៃឧបសម្ព័ន្ធ១ នៃ «ការណែនាំ» ត្រូវបានអនុវត្ត ។ ក្នុងករណីដែលការទូទាត់ កិច្ចសន្យានេះធ្វើឡើងនៅក្រៅគណនីពិសេសនីតិវិធីទាំងនេះត្រូវបានផ្លាស់ប្ដូរដើម្បីធានាថាឯកសារចម្លង ត្រឹមត្រូវចំនួនពីរច្បាប់នៃកិច្ចសន្យាព្រមទាំងពត៌មានផ្សេងៗទៀតដែលត្រូវផ្ដល់ជូនសមាគមសមស្រប តាមកថាខ័ណ្ឌ៣ ដែលបាននិយាយខាងលើត្រូវផ្ដល់ជូនសមាគមទុកជាភស្ដុតាងសមស្របតាមកថាខ័ណ្ឌ៤ នៃកម្មវិធី៤ របស់កិច្ចព្រមព្រៀងនេះ ។

(គ) បទបញ្ញត្តិនៃវាក្យខ័ណ្ឌ (ខ) ខាងលើមិនត្រូវបានអនុវត្តចំពោះកិច្ចសន្យាទាំងឡាយណាដែលការដកប្រាក់ពីគណនីឥណទាន គឺត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃស្ថានភាពចំណាយ ។

២–តួលេខចំនួនដប់ប្រាំភាគរយ (១៥%) ត្រូវបានកំណត់នៅទីនេះ ជាគោលបំណងនៃកថា ខ័ណ្ឌ ៤ នៃឧបសម្ព័ន្ធ១ នៃការណែនាំ ។

ផ្នែក II–ការប្រើប្រាស់អ្នកពិគ្រោះ

១–ដើម្បីជួយជ្រោមជ្រែងអ្នកខ្ចីក្នុងកិច្ចអនុវត្តគំរោងការ អ្នកខ្ចីនឹងប្រើប្រាស់អ្នកពិគ្រោះដែលមានគុណសម្បត្តិ បទពិសោធន៍ កាលកំណត់និងល័ក្ខខ័ណ្ឌនៃការងារត្រូវបំពេញទៅតាមសមាគម អ្នកពិគ្រោះទាំងនេះត្រូវបានជ្រើសរើស សមស្របទៅតាមគោលការណ៍ និងនីតិវិធីរបស់សមាគម ។ ដោយផ្អែកតាមការណែនាំនៃការប្រើប្រាស់អ្នកពិគ្រោះ របស់អ្នកខ្ចីនិងធនាគារពិភពលោកដែលជាភ្នាក់ងារ អនុវត្ត បោះពុម្ពផ្សាយដោយធនាគារនៅខែ សីហា ១៩៨១ (ការណែនាំអ្នកពិគ្រោះ) ។

២–ចំពោះកិច្ចការជ្រើសតាំងដ៏សំខាន់នេះ អ្នកខ្ចីជ្រើសរើសអ្នកពិគ្រោះទាំងនេះដោយធ្វើកិច្ចសន្យាតាមគំរូរបស់ធនាគារដែលអាចផ្លាស់ប្ដូរបានតាមការព្រមព្រៀងជាមួយសមាគម ។ ក្នុងករណី ដែលគ្មានឯកសារកិច្ចសន្យាជាគំរូចេញដោយធនាគារនោះអ្នកខ្ចីអាចប្រើប្រាស់លិខិតគំរូផ្សេងទៀត ដោយមានការយល់ព្រមពីសមាគមផង ។

៣–ដោយបដិបញ្ញត្តិចំពោះកថាខ័ណ្ឌ១ នៃផ្នែកនេះ បទបញ្ញត្តិនៃការណែនាំអ្នកពិគ្រោះដែលតម្រូវអោយមានការត្រួតពិនិត្យពីសមាគម រឺយល់ព្រមថវិកា បញ្ជីរាយនាមរយៈពេលខ្លី សំរាំងនីតិវិធីលិខិតប្រកាសចូលរួម សំណើរបាយការណ៍វាយតំលៃព្រមទាំងកិច្ចសន្យាផ្សេងៗ មិនត្រូវបានអនុវត្ត ចំពោះ : (ក) កិច្ចសន្យាជាមួយក្រុមហ៊ុនពិគ្រោះដែលមានតំលៃសមមូលតិចជាងមួយរយពាន់ដុល្លារ (១០០.០០០) ក្នុងមួយកិច្ចសន្យា រឺ (ខ) កិច្ចសន្យាជាមួយបុគ្គលពិគ្រោះដែល (ខ) តំលៃសមមូលតិច ជាងហាសិបពាន់ (៥០.០០០) ក្នុងមួយកិច្ចសន្យា ។ យ៉ាងណាក៏ដោយការលើកលែងនេះ ចំពោះការ ពិនិត្យជាមុនរបស់សមាគមមិនត្រូវបានអនុវត្ត : (i) ល័ក្ខខ័ណ្ឌបង្អែកនៃកិច្ចសន្យាទាំងនេះ (ii) ប្រភពជ្រើសរើសចេញពីក្រុមហ៊ុនតែមួយ (iii) កិច្ចការមានលក្ខណៈកំណត់ សមហេតុសមផលពីសមាគម (iv) វិសោធនកម្មចំពោះកិច្ច សន្យាដែលធ្វើជាមួយក្រុមហ៊ុនពិគ្រោះ ដែលតំលៃកិច្ចសន្យា សមមូល ឬ ច្រើនជាងមួយរយពាន់ដុល្លារ (១០០.០០០) រឺ (v) វិសោធនកម្មចំពោះកិច្ចសន្យាជ្រើសរើសបុគ្គលពិគ្រោះ ដែលមានតំលៃកិច្ចសន្យាសមមូល រឺច្រើនជាងហាសិបពាន់ដុល្លា (៥០.០០០០) ។

កម្មវិធី៤

គណនីពិសេស

១-គោលបំណងនៃកម្មវិធីនេះ

(ក) ពាក្យ « ប្រភេទជ្រើសតាំង »មានន័យថាប្រភេទ (១),(២),(៣),(៤) និង (៥) ដែលបានចែងក្នុងតារាងកថាខ័ណ្ឌ១ នៃកម្មវិធី១ ក្នុងកិច្ចព្រមព្រៀងនេះ ។

(ខ) ពាក្យ «ចំណាយជ្រើសតាំង» មានន័យថាចំណាយទៅតាមតម្លៃទំនិញ និងសេវាដ៏សមស្របរបស់គំរោងការ ហើយត្រូវបានហិរញ្ញសម្បទានពីចំនួនទឹកប្រាក់នៃគណនីពិសេស ផ្តល់អោយ «ប្រភេទជ្រើសតាំង» ជាបណ្តើរៗសមស្របតាមបទបញ្ញត្តិកម្មវិធី១ នៃកិច្ចព្រមព្រៀងនេះ និង

(គ) ពាក្យ «ប្រាក់វិភាគយល់ព្រម» មានន័យថា ចំនួនប្រាក់សមមូលមួយលានដុល្លារ (១,០០០,០០០) ត្រូវបានដកចេញពី គណនីឥណទាន ហើយត្រូវបានតំកល់ក្នុងគណនីពិសេស អនុលោមតាមកថាខ័ណ្ឌ ៣(ក) នៃ កម្មវិធីនេះ ។ ក៏ប៉ុន្តែបើពុំនោះទេ លុះត្រាតែសមាគមឯកភាព ប្រាក់វិភាគយល់ព្រមត្រូវបានកំរិតសមមូល បីរយពាន់ដុល្លារ (៣០០,០០០) រហូតដល់ទឹកប្រាក់សរុប ដែលត្រូវដកពីគណនីឥណទាន បូកចំនួនប្រាក់

សរុបដែលកំពុងស្ថិតនៅ ជាសន្យាពិសេសដោយធនាគារ អនុលោមតាមផ្នែក ៥,០២ នៃ «លក្ខខ័ណ្ឌទូទៅ » ស្មើនិងឬលើសចំនួនប្រាំពាន់ដុល្លារ (៥,០០០,០០០) ។

២–ការទូទាត់ពីគណនីពិសេស ធ្វើទៅបានចំពោះចំណាយ ជ្រើសតាំងតែប៉ុណ្ណោះ ស្របតាមបទបញ្ញត្តិនៃកម្មវិធីនេះ ។

៣–ក្រោយពេលដែលសមាគម បានទទួលសក្ខីភាព ជាទីពេញចិត្តហើយនោះ គណនីពិសេសត្រូវបានបើកនៅពេលមួយជាកំណត់ ការដកប្រាក់ជាវិភាជន៍យល់ព្រម និង ការដកប្រាក់លើកក្រោយៗ ទៀតដើម្បីបំពេញឡើងវិញអោយគណនីពិសេស នឹងត្រូវប្រព្រឹត្តិទៅដូចតទៅ :

(ក) ដើម្បីដកប្រាក់ វិភាជន៍យល់ព្រម អ្នកខ្ចី ត្រូវផ្តល់អោយសមាគម នូវពាក្យសុំមួយ ឬមួយចំនួនសំរាប់តម្កល់ក្នុងគណនីពិសេស ជាទឹកប្រាក់មួយឬទឹកប្រាក់ទាំងឡាយដែលកំណត់ដោយ សមាគមស្មើទូទាត់ចំពោះចំណាយ ជ្រើសតាំង ក្នុងរយៈពេលបួនខែទៅតាមការបរិច្ចេទនៃពាក្យស្នើសុំនិមួយៗដែលមានទឹកប្រាក់ មិនអោយលើសចំនួនទឹកប្រាក់សរុបនៃប្រាក់វិភាជន៍យល់ព្រម ។ ផ្អែកលើ មូលដ្ឋាន ស្នើសុំមួយ ឬមួយចំនួននេះ សមាគមនឹងដកប្រាក់ពីគណនីឥណទាន ក្នុងនាមអោយអ្នកខ្ចី ហើយបង្វែរចូលគណនីពិសេសសនូវចំនួនទឹកប្រាក់ទាំងនេះ ដែលសមាគម បានកំណត់ដូចដែល បានស្នើសុំ ។

(ខ) (i) ដើម្បីបំពេញគណនីពិសេសឡើងវិញ អ្នកខ្ចីត្រូវផ្តល់ ជូនសមាគមនូវពាក្យស្នើសុំសំរាប់បញ្ចូលក្នុងគណនីពិសេសនៅចន្លោះពេលដែលសមាគមនឹងបញ្ជាក់ជូន ។ (ii) មុន ឬនៅពេលដាក់ ពាក្យស្នើសុំ អ្នកខ្ចីត្រូវផ្តល់ ជូនសមាគមនូវឯកសារ និង សក្ខីប័ត្រ ។ៗទៀតសមស្រប កថាខ័ណ្ឌ៤ នៃ កម្មវិធីនេះដើម្បីស្នើសុំទូទាត់អ្វីមួយ ឬ ច្រើនមុខក្នុងបំណងដើម្បីបំពេញឡើងវិញ ។ ផ្អែកលើ មូលដ្ឋាននៃសំណើសុំនិមួយៗនេះ ក្នុងនអោយ[illegible] សមាគមធ្វើការដកប្រាក់នេះ ដូចដែលអ្នកខ្ចីបាន ស្នើសុំនិងដូចបានបញ្ជាក់បង្ហាញនៅក្នុងឯកសារ និងសក្ខីប័ត្រផ្សេងៗបានទូទាត់រួចមកហើយពីគណនី ពិសេសចំពោះចំណាយ ជ្រើសតាំងទាំងនោះ ។ គ្រប់ប្រាក់បញ្ញើទាំងនេះ ត្រូវបានសមាគមដក[illegible] គណនីឥណទានក្រោមប្រភេទ ជ្រើសតាំងនានា និងបិតនៅក្នុង ចំនួនទឹកប្រាក់ត្រូវគ្នាដូចដែលបាន បញ្ជាក់នៅក្នុងឯកសារ និងសក្ខីប័ត្រផ្សេងៗ ដែលបានផ្ញើជូន ។

៤–ចំពោះការទូទាត់និមួយៗ ដែលអ្នកខ្ចី បានធ្វើឡើងពីគណនីពិសេស នៅពេលនោះ សមាគមទាមទារអោយអ្នកខ្ចី ផ្តល់ជូននូវឯកសារ និង សក្ខីប័ត្រផ្សេងៗទាំងនេះដើម្បីបង្ហាញប្រាប់ថាការទូទាត់នេះបានធ្វើឡើងត្រឹម ត្រូវដាច់ខាតអោយមុខចំណាយជ្រើសតាំងប៉ុណ្ណោះ ។

៥–ដោយបដិប្បញ្ញត្តិ ចំពោះកឋាខ័ណ្ឌ៣ នៃកម្មវិធីនេះ សមាគមមិនត្រូវការទាមទារ អោយធ្វើការតំកល់ប្រាក់ជាលំអិតក្នុងគណនីពិសេសទេ :

(ក) នៅពេលមួយ បើសមាគម បានកំណត់ឃើញថា ការដកប្រាក់ជាលំអិត ទាំងអស់ត្រូវបានធ្វើឡើងដោយអ្នកខ្ចី ទៅតាមបែបបទផ្ទាល់ពីគណនីឥណទាន សមស្របតាមបទបញ្ញត្តិនៃមាត្រារបស់ «ល័ក្ខខ័ណ្ឌទូទៅ » និងតាមកឋាខ័ណ្ឌផ្នែក ២,០២ នៃកិច្ចព្រមព្រៀងនេះ ។

(ខ) បើអ្នកខ្ចី មានការខ្វះខាតក្នុងការ ផ្តល់ជូនសមាគម ក្នុងរយៈពេលដែលបានកំណត់ ក្នុងផ្នែក ៤ ,០១ នៃកិច្ច ព្រមព្រៀងនេះរបាយការណ៍ត្រួតពិនិត្យគណនីត្រូវផ្តល់ជូន សមាគម អនុលោមតាមផ្នែកដែលនិយាយនេះ ស្តីពីការត្រួតពិនិត្យកិច្ចបញ្ជីកា និងគណនីទាំងឡាយចំពោះគណនីពិសេស។

(គ) នៅពេលណាមួយ បើសមាគមបានប្រកាសដល់អ្នកខ្ចី នូវគោលបំណងរបស់គេសូមបញ្ឈប់សិទ្ធិរបស់អ្នកខ្ចី ស្នើការដកប្រាក់ ទាំងស្រុងឬ មួយចំណែកណានោះ ចេញពីគណនីឥណទាន ដោយអនុលោមតាមបទ បញ្ញត្តិនៃផ្នែក ៦,០២ របស់ «ល័ក្ខខ័ណ្ឌ » ឬ

(ឃ)នៅពេលដែល ចំនួនសរុបឥណទាន មិនបានដកពីប្រភេទជ្រើសតាំងដក (–) ចំនួនប្រាក់រង់ចាំទូទាត់នៃការ សន្យាពិសេស ដែលបានព្រមព្រៀងដោយសមាគម សមស្របតាមផ្នែក ៥,០២ នៃល័ក្ខខ័ណ្ឌទូទៅសំរាប់ គំរោងការ គិតជាសមមូលស្មើ នឹងពីរដងនៃ «ចំនួនប្រាក់ដែលបាន អនុញ្ញាត្តិ » ។ ក្រោយពីនេះ ការដកប្រាក់ពីគណនីឥណទានដែលជាចំនួនឥណទាន នៅសល់មិន បានដកសំរាប់ប្រភេទជ្រើសតាំងអាចបន្តតាមនីតិវិធីដែលសមាគម នឹងបញ្ជាក់តាមប្រកាសជូនអ្នកខ្ចី។ ការដកប្រាក់តទៅទៀត អាចស្នើទៅបានក្រោយពីសមាគមបានយល់ឃើញថា ចំនួនប្រាក់នៅសល់ក្នុង គណនីពិសេសពីអំណឹរតទៅ នៃការប្រកាស នេះត្រូវបានប្រើប្រាស់ក្នុងការទូទាត់ សំរាប់ចំណាយជ្រើសតាំង ។

៦–(ក) បើសមាគមបានកំណត់វិញថាខ្វះការទូទាត់ចេញពី គណនីពិសេស (i) បានធ្វើឡើងសំរាប់ចំណាយណាមួយ ឬក្នុងចំនួនប្រាក់មួយចំនួន នៅក្រៅការជ្រើសតាំង ដោយអនុលោមតាមកឋាខ័ណ្ឌ២ នៃកម្មវិធីនេះ ។ ឬ (ii) ពុំបានធ្វើយុត្តិកម្មជាសក្ខីប័ត្រត្រឹមត្រូវផ្តល់ជូនសមាគមនោះផ្នែកតាមប្រកាសរបស់សមាគម អ្នកខ្ចី ត្រូវប្រុងប្រៀប (ក) ផ្តល់សក្ខីប័ត្រជាលំអិតទាំងនេះនៅពេល សមាគមត្រូវការ ឬ (ខ) តម្កល់ទឹកប្រាក់អោយស្មើនឹងចំនួនប្រាក់ទូទាត់នេះឬស្មើនិងចំណែកទឹកប្រាក់ ដែលនៅក្រៅការជ្រើសតាំង ឬ ពុំបានធ្វើយុត្តិកម្ម ចូលក្នុងគណនីពិសេសវិញ (ឬត្រូវសងជូនសមាគម វិញក្នុងករណីសមាគម

ត្រូវការ) ។ លើកលែងសមាគមយល់ព្រមប្រាក់បញ្ញើជាថ្មីរបស់សមាគមចូលក្នុងគណនីពិសេសពុំអាចធ្វើទៅបានឡើយរហូតដល់អ្នកខ្ចីបានផ្តល់សក្ខីប័ត្រ ទាំងនេះឬបានតម្កល់ប្រាក់ ឬ បានសងប្រាក់រួចរាល់តាមករណីដែលអាចកើតមានឡើង ។

(ខ) នៅពេលណាមួយបើសមាគមបានកំណត់ឃើញថា ចំនួនប្រាក់ដែលកំពុងជំពាក់នៅក្នុងគណនីពិសេសមិនបានទាមទារ សំរាប់ការទូទាត់បន្តអោយចំណាយជ្រើសតាំងនោះ ផ្អែកតាមប្រកាសរបស់សមាគមអ្នកខ្ចីត្រូវសងចំនួនប្រាក់ជំពាក់នេះអោយសមាគមជាបន្ទាន់ ។

(គ) ផ្អែកតាមប្រកាស ជូនសមាគម អ្នកខ្ចីត្រូវសងទាំងអស់ ឬចំណែកណាមួយនៃមូលនិធិប្រាក់បញ្ញើនៅក្នុងគណនីពិសេស ។

(ឃ) ការសងប្រាក់ជូនសមាគម ដែលធ្វើឡើងដោយអនុលោមតាមកថាខ័ណ្ឌ ៦ (ក) (ខ) និង (គ) នៃកម្មវិធីនេះត្រូវបានចុះឥណទានអោយ «គណនីឥណទាន » សំរាប់ការដកប្រាក់នៅពេលក្រោយឬសំរាប់ការលុបចោលផ្អែកតាមបទបញ្ញត្តិ ដ៏សមហេតុសមផល នៃកិច្ចព្រមព្រៀងនេះ រួមទាំង លក្ខខ័ណ្ឌទូទៅ » ផង ។

* * *

ផែនការអនុវត្តគំរោង

អាទិភាព គំរោង	សកម្មភាព គំរោងសំខាន់ៗ	កំណត់ កាលបរិច្ឆេទ	កម្មវិធីការងារ ចំណុចសំខាន់ៗ	កំណត់កាលបរិច្ឆេទ
ការពិនិត្យចំណាយសាធារណៈ «ការងារគ្រប់គ្រងថវិកា និងរតនាគារ» ពង្រឹង : -សមត្ថភាពធ្វើគំរោងថវិកា -ត្រួតពិនិត្យចំណាយ -គ្រប់គ្រងសាច់ប្រាក់រតនាគារ	ប្រើសេវា : -ទីប្រឹក្សាហិរញ្ញវត្ថុសាធារណៈ (SPF) -ទីប្រឹក្សាថវិកា និង រតនាគារ (SBT) -អ្នកបច្ចេកទេសថវិកា ៥ រូប (BTS) -ជំនាញគណនេយ្យសាធារណៈរតនាគារ ផ្គត់ផ្គង់ : -បរិក្ខារការិយាល័យ	មករា ១៩៩៥ មករា ១៩៩៥ មករា-មិថុនា ១៩៩៥ មីនា ១៩៩៥ ១៩៩៥-៩៥	រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំសំរាប់បុគ្គលិកសមភាគី រៀបចំកម្មវិធី T&V សំរាប់សមភាគីបុគ្គលិកតាមក្រសួងនានា និងខេត្ត-ក្រុង ដាក់ចែងសំរេចក្របខ័ណ្ឌស្ថាប័ន សំរាប់ត្រួតពិនិត្យចំណាយ បង្កើតក្រុមដំបូង នៃមន្ត្រីអធិការហិរញ្ញវត្ថុ រៀបចំសន្និបាតបូកសរុបថវិកាប្រចាំឆ្នាំ ដាក់ចែងសំរេចប្រព័ន្ធសំរាប់គ្រោងចំណូល និងចំណាយប្រចាំខែ ដាក់ចែងសំរេចវិធាន និងនីតិវិធីសំរាប់ប្រមូលចំណូល និងកិច្ចប្រតិបត្តិការចំណាយ -រៀបចំឡើងវិញ នូវគណនីរតនាគារ ទៅតាមតារាងលេខនាមថវិកាថ្មី -បង្កើតវិធានថ្មី សំរាប់គ្រប់គ្រងគណនីរតនាគារ	៣១ មីនា ៣១ មីនា ៣១ ធ្នូ ១៩៩៦ ៣១ ធ្នូ ១៩៩៥ ៣០ កញ្ញា ៣១ ធ្នូ ១៩៩៥ ៣១ ធ្នូ ១៩៩៥ ៣១ ធ្នូ ១៩៩៥ ៣១ ធ្នូ ១៩៩៥
ការងារគ្រប់គ្រងវិនិយោគសាធារណៈ -ពង្រឹងការងារកម្មវិធីវិនិយោគសាធារណៈ -អភិវឌ្ឍសមិទ្ធកម្មថវិកាវិនិយោគសាធារណៈ -ពង្រឹងអង្គភាពគំរោងតាមក្រសួងនានា -ពង្រឹងសម្របសម្រួលជំនួយ -ពង្រឹងផែនការកម្មជាយុទ្ធសាស្ត្រ -អភិវឌ្ឍសមត្ថភាពវិភាគម៉ាក្រូ	អង្គភាព PIP និង អភិវឌ្ឍប្រព័ន្ធ PIP ប្រើសេវា-សំរាំង -ទីប្រឹក្សា PIB -ជំនាញការទាក់ទង PIB -វិស្វករប្រព័ន្ធកុំព្យូទ័រ CSE -អ្នកផ្គត់ផ្គង់ប្រព័ន្ធ ផ្គត់ផ្គង់ : -បរិក្ខារការិយាល័យ	 មីនា ១៩៩៥ មីនា ១៩៩៥ មិថុនា ១៩៩៥ វិច្ឆិកា ១៩៩៥ ១៩៩៥-៩៦	បង្កើតអង្គភាព PLB ទាក់ទងបុគ្គលិក រៀបចំកម្មវិធីបណ្តុះបណ្តាល សំរាប់បុគ្គលិកសមភាគី រៀបចំកម្មវិធី T&V សំរាប់បុគ្គលិកសមភាគី តាមក្រសួងនានា រៃបចំចែកប្រព័ន្ធពត៌មានវិទ្យា និង បណ្តុះបណ្តាលបុគ្គលិកប្រើប្រាស់ និង ថែទាំ CSE សំរាប់គ្រប់គ្រង រៃបចំចែកប្រព័ន្ធកុំព្យូទ័រ និង បណ្តុះបណ្តាល រៃបចំចែកសំភារៈបរិក្ខារការិយាល័យ	៣១ ធ្នូ ១៩៩៥ ១៩៩៥-៩៦ ១៩៩៥-៩៧ មីនា ១៩៩៦ មករា-មីនា ៩៦ មេសា -ធ្នូ ១៩៩៥
	អង្គភាពគំរោងការតាមក្រសួងនានា ប្រើសេវា : -ឯកទេសគ្រប់គ្រងគំរោង -ឯកទេសសមិទ្ធកម្ម កម្មវិធី -គណនេយ្យករ គំរោងការ -គណនេយ្យករទូទៅ-ស្នងការគណនី -ឯកទេសទាក់ទង ០២ រូប	 មករា ១៩៩៦ មករា ១៩៩៦ មករា ១៩៩៦ មករា ១៩៩៦	អភិវឌ្ឍនីតិវិធី សំរាប់ត្រួតពិនិត្យតាមដានគំរោង រៀបចំ ចងក្រងអត្ថបទសៀវភៅ រៃបចំចែកប្រព័ន្ធកុំព្យូទ័រ ផ្សារភ្ជាប់ប្រព័ន្ធ PIB នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បណ្តុះបណ្តាលបុគ្គលិក ប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ	៣០ មិថុនា ១៩៩៦ ៣១ ធ្នូ ១៩៩៦ ១៩៩៦-៩៧ មិថុនា ១៩៩៦

ផែនការអនុវត្តគំរោង

	<u>ផែនការកម្មវិធីយុទ្ធសាស្ត្រ និងសំរបសំរួលជំនួយ</u> ជ្រើសរើស –ទីប្រឹក្សាសំរបសំរួលជំនួយ មករា ១៩៩៥ –អ្នកពិគ្រោះសំរាប់ទស្សនៈអនាគត មិថុនា ១៩៩៥ –ជនជាតិកម្ពុជាមកពីក្រៅ ១៩៩៥ <u>ផ្គត់ផ្គង់</u> : –បរិក្ខារការិយាល័យ ១៩៩៥/៩៦	បង្កើតមូលនិធិសិក្សា ៣១ មិថុនា ១៩៩៧ រៀបចំ និង អនុវត្តកម្មវិធីបណ្តុះបណ្តាល ++ ធ្វើសេចក្ដីយល់ «ទស្សនៈ» សិក្សានៅឧត្តមសិក្សា ៣១ មីនា ១៩៩៦ បែងចែកប្រព័ន្ធកុំព្យូទ័រ ភ្ជាប់ប្រព័ន្ធ PIB នៅ គសហវ មីនា ១៩៩៦ បែងចែកបរិក្ខារការិយាល័យ ១៩៩៥/១៩៩៦
	<u>វិភាគម៉ាក្រូសេដ្ឋកិច្ច</u> ជ្រើសរើស –ទីប្រឹក្សាប្រចាំអង្គភាពសេដ្ឋកិច្ច គសហវ មករា ១៩៩៥ <u>ផ្គត់ផ្គង់</u> –បរិក្ខារការិយាល័យ ១៩៩៥–៩៦	រៀបចំកម្មវិធីបណ្តុះបណ្តាល សំរាប់ព្យាករណ៍ វិភាគសេដ្ឋកិច្ច ។ល។ ៣១ ធ្នូ ១៩៩៥ បង្កើតទិន្នន័យមូលដ្ឋាន ៣១ ធ្នូ ១៩៩៦ អភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ៣១ មីនា ១៩៩៧ បែងចែកបរិក្ខារការិយាល័យ ១៩៩៥/១៩៩៦
<u>ការគ្រប់គ្រងបំណុល</u> : –អភិវឌ្ឍក្របខ័ណ្ឌស្ថាប័ន សំរាប់ការគ្រប់គ្រងបំណុលក្រៅប្រទេស –ពង្រឹងសមត្ថភាពសំរាប់ធ្វើចរចាការណ៍បំណុលជួនធនាគារពិភពលោក	ជ្រើសរើស/សំរាំង –ជំនាញការស្ថាប័នក្នុងការគ្រប់គ្រង មីនា ១៩៩៥ –ជំនាញការចាត់តាំង/ផែនការរួម មិថុនា ១៩៩៥ –វិស្វករប្រព័ន្ធកុំព្យូទ័រ(CSE) ធ្នូ ១៩៩៥ –អ្នកផ្គត់ផ្គង់ប្រព័ន្ធ មិថុនា ១៩៩៥ <u>ផ្គត់ផ្គង់</u> –បរិក្ខារការិយាល័យ	អភិវឌ្ឍក្របខ័ណ្ឌស្ថាប័នសំរាប់ការគ្រប់គ្រងបំណុល ១៩៩៥/១៩៩៦ រៀបចំផែនការសកម្មភាពសំរាប់ចរចាការណ៍បំណុលក្រៅប្រទេស មីនា ១៩៩៥ រៀបចំផែនការរួមសំរាប់អង្គភាពបំណុលថ្មី ៣១ តុលា ១៩៩៥ រៀបចំកម្មវិធីបណ្តុះបណ្តាល «ក្រៅពីកុំព្យូទ័រ» សំរាប់គ្រប់គ្រងបំណុលក្រៅប្រទេស ៣១ ធ្នូ ១៩៩៥ អនុវត្តរចនាសម្ព័ន្ធចាត់តាំងថ្មី និង ផែនការបណ្តុះបណ្តាលអង្គភាពបំណុល ៣១ ធ្នូ ១៩៩៦ បែងចែកប្រព័ន្ធកុំព្យូទ័រ និង បណ្តុះបណ្តាលបុគ្គលិក ៣០ មិថុនា ១៩៩៧ ដើម្បីប្រើប្រាស់ និង ថែទាំ ១៩៩៦/១៩៩៧ (CSE) តាមដានត្រួតពិនិត្យបែងចែកប្រព័ន្ធកុំព្យូទ័រ និង បណ្តុះបណ្តាល បែងចែកបរិក្ខារការិយាល័យ ១៩៩៥/១៩៩៧
<u>ការគ្រប់គ្រងបុគ្គលិក</u> –រួមចំណែកការកែទំរង់រដ្ឋបាល –អភិវឌ្ឍយុទ្ធសាស្ត្រ សំរាប់បន្ថយទំហំក្របខ័ណ្ឌមន្ត្រីរាជការ និង ផ្នែកសហគ្រាសសាធារណៈ PE	ជ្រើសរើស : –ក្រុមហ៊ុនពិគ្រោះ មេសា ១៩៩៥ –ទីប្រឹក្សាសហគ្រាសសាធារណៈ មករា ១៩៩៥	ពីគត់ត្រួតពិនិត្យគណនីសហគ្រាសសាធារណៈ ដើម្បីលុបឈ្មោះនិយោជិក – ប្រមូលទិន្នន័យលើផលវិបាកផលវិជ្ជមាន និង ចំណាយ ៣១ ធ្នូ ១៩៩៥ ស្នើគោលនយោបាយលើការមន្ត្រីរាជការថ្មី ៣០ មិថុនា ១៩៩៦ ធ្វើសំណើកំណែទំរង់ការងារនៅរដ្ឋបាល ៣១ ធ្នូ ១៩៩៦ សិក្សាពីលក្ខខណ្ឌដំណើរការ ៣១ ធ្នូ ១៩៩៦ សិក្សាផែនការសោធន និង ប្រព័ន្ធធានាសង្គម ៣០ មិថុនា ១៩៩៧

កម្មវិធី ៥ «គ»

ផែនការអនុវត្តគំរោង

<u>ជំនួយការច្បាប់ សំរាប់អភិវឌ្ឍន៍វិស័យឯកជន</u> -អភិវឌ្ឍន៍កម្លាំងសំខាន់ៗ មួយចំនួន នៃ..... បរិដ្ឋានគតិយុត្ត សំរាប់ -ពង្រឹងសមត្ថភាពសំរាប់និពន្ធ និង បណ្តុះបណ្តាល	ជ្រើសរើស : -ទីប្រឹក្សាច្បាប់សំរាប់ -ទីប្រឹក្សាច្បាប់សំរាប់ -ជំនាញការច្បាប់សំរាប់សិក្ខាសិលា និងវាយតំលៃតំរូវការ បណ្តុះបណ្តាល -ជំនាញការច្បាប់សំរាប់និពន្ធនិងបណ្តុះបណ្តាលផែនការរួម -ឯកទេសច្បាប់សំរាប់ប្រាក់កិច្ច និង យុត្តិសាស្ត្រ -ឯកទេសស្ថាប័ន ផ្គត់ផ្គង់ : បរិក្ខារការិយាល័យ និង បោះពុម្ព	បង្កើនសមត្ថភាពនៃទំរង់គតិយុត្ត នៅក្រុមប្រឹក្សាអ្នកច្បាប់ ៣០ មិថុនា ១៩៩៥ អនុមតិសភាពការណ៍ជាផ្លូវការ លើច្បាប់អាទិភាពសេដ្ឋកិច្ច និង ៣១ ធ្នូ ១៩៩៥ ហិរញ្ញវត្ថុ អនុវត្តការសិក្ខាសិលា គតិយុត្ត ៣១ ធ្នូ ១៩៩៥ អនុវត្តវាយតំលៃ តំរូវការបណ្តុះបណ្តាលគតិយុត្ត ៣០ មិថុនា ១៩៩៦ រៀបចំ-អនុវត្តរយៈពេលផែនការរួមសំរាប់និពន្ធគតិយុត្តនិងបណ្តុះបណ្តាលផែនការ ៣១ ធ្នូ ១៩៩៦ រៀបចំ និងអនុវត្តផែនការសកម្មភាពបង្កើតពាណិជ្ជកម្មឡើងវិញ ៣១ ធ្នូ ១៩៩៥ រៀបចំ និង អនុវត្តផែនការសកម្មភាព បង្កើតប្រព័ន្ធលេខកូដ គតិយុត្តិ ៣១ ធ្នូ ១៩៩៦ បង្កើតផែនការសកម្មភាព សំរាប់អភិវឌ្ឍន៍ក្របខ័ណ្ឌយុត្តិសាស្ត្រ ៣០ មិថុនា ១៩៩៦ ចែងចែកបរិក្ខារ កុំព្យូទ័រ បោះពុម្ព និង បណ្តុះបណ្តាលបុគ្គលិក ១៩៩៥/៩៦ ប្រើប្រាស់ និង ថែទាំបរិក្ខារទាំងនេះ
<u>ការអប់រំច្បាប់ប្រព័ន្ធបណ្តុះបណ្តាល និង ហិរញ្ញវត្ថុ</u> -ផ្គត់ផ្គង់ទីកន្លែង និង បរិដ្ឋានសមស្រប សំរាប់បណ្តុះបណ្តាល	ជ្រើសរើស : -អ្នកសម្របសម្រួល បណ្តុះបណ្តាលសាងសង់ កញ្ញា ១៩៩៥ -សំភារៈបណ្តុះបណ្តាល ១៩៩៥	ដាក់តែងសំរេចការសិក្សា និង ផែនការអគារបណ្តុះបណ្តាល មករា ១៩៩៥ បញ្ចប់ការសាងសង់ បរិក្ខារបណ្តុះបណ្តាល មករា ១៩៩៦ រៀបចំមេរៀន បង្រៀនបុគ្គលិក ** តាមដានត្រួតពិនិត្យ សកម្មភាពបណ្តុះបណ្តាលរបស់អ្នកពិគ្រោះគំរោង **

កម្មវិធី ៥ «តចប់»

ផែនការអនុវត្តគំរោង

មូលនិធិសិក្សា	ជ្រើសរើស :		អ្នកសម្របសម្រួលជំនួយ រៀបចំវិធានគ្រប់គ្រងមូនិធិសិក្សា	៣០ មិថុនា ១៩៩៥
សិក្សាអាទិភាពហិរញ្ញវត្ថុសកម្មភាព	ទីប្រឹក្សាសម្របសម្រួលជំនួយ CDC		រៀបចំលក្ខណៈទូទៅ TOR សំរាប់សិក្សាសកម្មភាព	+
មិនទាន់ធ្វើអក្ខសញ្ញាណកម្មច្បាប់លាស់		មករា ១៩៩៥	ហិរញ្ញប្បទានដោយមូលនិធិ	
ពេលប្រជុំវាយតំលៃ ឬក្នុងវិស័យក្រៅគំរោង			ធានាការប្រើប្រាស់តាមលទ្ធភាពដ៏ល្អប្រសើរ នៃការសិក្សា	
អង្គភាពគ្រប់គ្រងគំរោងឈ :	តែងតាំងឬជ្រើសរើស		បង្កើតគណនីពិសេស នៅធនាគារជាតិនៃកម្ពុជា NBC	មករា ១៩៩៥
	–អ្នកសម្របសម្រួលគំរោង	តុលា ១៩៩៤	ប្រជុំទៀងទាត់ នៃក្រុមអនុវត្តគំរោង	**
	–អភិបាលគំរោង	វិច្ឆិកា ១៩៩៤	ចាត់ចែងសិក្ខាសាលាលើកទី ១ សំរាប់បុគ្គលិក PAG: និង	៣១ មីនា *
	–គណនេយ្យករគំរោង	វិច្ឆិកា ១៩៩៤	ក្រុមនាយកគំរោងការ PCD	
	–ទីប្រឹក្សាគំរោង	វិច្ឆិកា ១៩៩៤	បូកសរុបគំរោងប្រចាំឆ្នាំជាមួយធនាគារជាតិពិភពលោក	៣១ មីនា *
	–បុគ្គលិក	មករា ១៩៩៥	បូកសរុបរយៈពេលមធ្យមនៃគំរោងជាមួយធនាគារពិភពលោក	៣០ មិថុនា ១៩៩៧
	ផ្គត់ផ្គង់ :		សុក្រឹត្យកម្មនៃកម្មវិធីការងារប្រចាំឆ្នាំ និង របាយការណ៍សន្ទុះឆ្នាំ	៣១ ធ្នូ *
	–សំភារៈបរិក្ខារការិយាល័យ		ធ្វើត្រួតពិនិត្យគណនីគំរោងប្រចាំឆ្នាំ ជូនធនាគារពិភពលោក	*
	–យានយន្ត		ផ្ញើរបាយការណ៍បញ្ចប់គំរោងទៅធនាគារពិភពលោក	***
			ផ្ញើផែនការសំរាប់ប្រតិបត្តិការគំរោងអនាគត	***

<u>កំណត់សំគាល់</u> :កំណត់កាលបរិច្ឆេទ គឺជាកលបរិច្ឆេទ ដែលសកម្មភាពនឹងប្រព្រឹត្តទៅ

* ប្រចាំឆ្នាំ

** ទៀងទាត់តាមតម្រូវការញឹកញាប់

*** មិនហួស ៦ ខែ ក្រោយកាលបរិច្ឆេទបញ្ចប់ឥណទាន

\+ ពេលណាត្រូវការ

\++ ជាអចិន្ត្រៃយ៍

CREDIT NUMBER 2664 KH

Development Credit Agreement

(Technical Assistance Project)

between

KINGDOM OF CAMBODIA

and

INTERNATIONAL DEVELOPMENT ASSOCIATION

KINGDOM OF CAMBODIA

December 16, 1994

International Development Association
1818 H Street, N.W.
Washington, D.C. 20433
United States of America

Re : Credit No. 2664 KH
(Technical Assistance Project)
Section 9.02 of the General Conditions
<u>Financial and Economic Data</u>

Dear Sirs :

In connection with the Credit to the Kingdom of Cambodia in an amount in various currencies equivalent to SDR 11,600,000 for the Technical Assistance Project, I am writing on behalf of the Kingdom of Cambodia to set forth the following:

1. We understand and agree that, for purposes of Section 9.02 of the General Conditions Applicable to Development Credits, the Kingdom of Cambodia is required by the Association to report new " loan commitments" (as defined in the Bank's Debtor Reporting System Manual, dated January 1989) not later than 30 days after the end of the quarter during which the debt is incurred, and to report " transactions under loans" (as so defined) not later than March 31 of the year following that for which the report is made.

2. We represent that no defaults exist in respect of any external public debt.

It is our understanding that, in making the Credit, the Association may rely on the statements set forth or referred to in this letter.

Very truly yours.
Kingdom of Cambodia

By--------------------------
Authorized Representative

CREDIT NUMBER 2664 KH

DEVELOPMENT CREDIT AGREEMENT

AGREEMENT, dated December 16 , 1994, between KINGDOM OF CAMBODIA (the "Borrower") and INTERNATIONAL DEVELOPMENT ASSOCIATION (the "Association").

WHEREAS: (A) the Borrower, having satisfied itself as to the feasibility and priority of the Project described in Schedule 2 to this Agreement , has requested the Association to assist in the financing of the Project ; and

WHEREAS : (B) The Association has agreed, on the basis, inter alia, of the foregoing , to extend the Credit to the Borrower upon the terms and conditions set forth in this Agreement.

NOW THEREFORE the parties hereto hereby agree as follows:

ARTICLE I

General Conditions; Definitions

Section 1.01. The " General Conditions Applicable to Development Credit Agreements " of the Association, dated January 1, 1985, with the last sentence of Section 3.02 deleted (the " General Conditions") constitute an integral part of this Agreement.

Section 1.02. Unless the context otherwise requires, the several terms defined in the General Conditions and in the Preamble to this Agreement have the respective meanings therein set forth and the following additional terms have the following meanings:

(a) "CDC" means the Council for the Development of Cambodia, established pursuant to the Borrower's Law on Investment of the Kingdom of Cambodia , as promulgated on August 5, 1994;

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និង លោក **ខា យុគា** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

២-សេចក្តីប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីប្រកាសលេខ ០៤ ប្រ.ក

របស់

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

* * *

ប៉ុន្មានថ្ងៃកន្លងមកនេះ មេដឹកនាំពួកឧទ្ទាមចោរព្រៃ ដែលមុននេះហៅថា ខ្មែរក្រហម បានធ្វើការប្រកាសជាបន្តបន្ទាប់ តាមវិទ្យុលួចលាក់របស់ខ្លួននូវអ្វីដែលពួកគេហៅថា «ការចរចា» រវាងរាជរដ្ឋាភិបាល និង ពួកឧទ្ទាម ។

នេះជាឧបាយកលដ៏ពិសពុលថ្មីមួយទៀតរបស់មេក្លោងពួកឧទ្ទាម សំដៅបិទបាំងនូវបរាជ័យរបស់ពួកគេ ព្រមទាំងបំភាន់សាធារណមតិជាតិ និង អន្តរជាតិក្នុងពេលដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងដំណើរការស្តារ និង អភិវឌ្ឍន៍ប្រទេសជាតិ ។

រាជរដ្ឋាភិបាលកម្ពុជា សូមប្រកាសបញ្ជាក់ជូនជនរួមជាតិ និង សាធារណមតិអន្តរជាតិជាថ្មីថា គ្មានការចរចាណាមួយរវាងរាជរដ្ឋាភិបាលកម្ពុជា ដែលជារដ្ឋាភិបាលស្របច្បាប់របស់ជាតិ កើតឡើងពីឆន្ទៈ ប្រជារាស្ត្រតាមរយៈការបោះឆ្នោត ជាមួយមេក្លោងពួកឧទ្ទាម ដែលត្រូវសភាជាតិ អនុម័តដាក់អោយស្ថិតនៅ ក្រៅច្បាប់តាំងពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៤ នោះឡើយ ទោះនៅទីកន្លែងណា និង ពេលវេលាណាក៏ដោយ ។

បច្ចុប្បន្ននេះ ពួកឧទ្ទាមដែលនៅសេសសល់កម្លាំងតិចតួច លាក់ខ្លួនក្នុងព្រៃ និង តាមតំបន់ព្រំដែនកំពុងបន្តធ្វើសកម្មភាពរបៀបចោរព្រៃ បំផ្លិចបំផ្លាញអាយុជីវិត និង ទ្រព្យសម្បត្តិប្រជារាស្ត្រស្លូតត្រង់ ព្រមទាំងទ្រព្យសម្បត្តិជាតិ ។ តាមផ្លូវច្បាប់ ពួកឧទ្ទាមចោរព្រៃគ្មានសិទ្ធិបង្កើតប្រព័ន្ធ រដ្ឋបាលអ្វីទាំងអស់ ទោះក្នុងរូបភាពណាក៏ដោយរួមទាំងរបស់អ្វីដែលហៅថា «រដ្ឋាភិបាលបណ្តោះអាសន្ន» របស់ពួកគេនោះផង ។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគ្មានហេតុផលណាមួយដែល ត្រូវចរចាជាមួយមេក្លោង នៃពួកឧទ្ទាមចោរព្រៃប្រល័យពូជសាសន៍នោះឡើយ ។

ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា នៅតែបើកទ្វារចំហរជានិច្ច ចំពោះអស់លោកនាយទាហាន ពលទាហានរបស់ពួកឧទ្ទាម ដែលកំពុងត្រៀមខ្លួន ឬ ក៏បានទំលាក់អាវុធវិលមក

រួមរស់ជាមួយរាជរដ្ឋាភិបាល និង សង្គមជាតិ ដូចប្រជាពលរដ្ឋខ្មែរស្លូតត្រង់ដទៃ ស្របតាមព្រះរាជតំរិះដ៏ខ្ពង់ខ្ពស់ប្រកបដោយក្តីមេត្តាធម៌ និង សណ្តោសប្រណីរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ បើមេដឹកនាំពួកឧទ្ទាមចង់ចូលរួមក្នុងឆាកនយោបាយនៅកម្ពុជា ពួកគេត្រូវតែរំសាយចោលរាល់អង្គការចាត់តាំងទាំងនយោបាយ និង យោធា ហើយវិលមករួមរស់ជាមួយនឹងសង្គមជាតិ ដោយអនុវត្ត ត្រឹមត្រូវ និង គោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្លៀតឱកាសនេះ រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវចំពោះអស់លោកនាយទាហាន ពលទាហាន និងបងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្រោមការត្រួតត្រាជាបណ្តោះអាសន្នរបស់មេក្លោងក្បាលរឹងនៃពួក ឧទ្ទាម ចូរប្រញាប់រិះរកវិធីវិលមករួមរស់ក្នុងសង្គមជាតិវិញ ដូចដែលរាជរដ្ឋាភិបាលកម្ពុជា ធ្លាប់បានធ្វើការអំពាវនាវជាច្រើនលើកច្រើនសារួចមកហើយ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III .ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១០៣ សហវ.ប្រក.ម

ស្តីពីការប្រល់ភារកិច្ច សំរួលភារកិច្ច និង

បន្ថយឋានៈមន្ត្រី រាជការរតនាគារខេត្តក្រចេះ

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញជំពូកទី ០៥ (វិន័យ) ក្នុងមាត្រាទី ៣៣-៣៨-៣៩ និង ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ នស. ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញលិខិតលេខ ៤៨ អក.៩៥ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់អយ្យការអមតុលាការខេត្តក្រចេះ ស្តីពីសំណើសុំចោទប្រកាន់ឈ្មោះ **ហែម វណ្ណយុត្តិ** ភេទប្រុស **យឹម និមល** ភេទស្រី និង **លឹម ឡាទី** ភេទស្រី មន្ត្រីធនាគារខេត្តក្រចេះ
- យោងរបាយការណ៍ ចុះថ្ងៃទី ២៧ នៃកក្កដា ឆ្នាំ ១៩៩៥ របស់ធនាគារជាតិ ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យការងារគ្រប់គ្រងសាច់ប្រាក់ និង ការអនុវត្តន៍ជំនាញចុះកិច្ចបញ្ជីការគណនេយ្យ នៃធនាគារខេត្តក្រចេះ
- តាមសំណើរបស់ធនាគារជាតិ

សម្រេច

មាត្រា ១ : ប្រគល់ភារកិច្ច សំរួលភារកិច្ច និង បន្ថយឋានៈមន្ត្រីរាជការធនាគារ នៃធនាគារខេត្តក្រចេះ ដូចមានរាយនាមខាងក្រោម ÷

១-ប្រគល់ភារកិច្ច លោកស្រី **កៅ យ៉ាងឆេង** ជាអនុប្រធានធនាគារអោយទទួលបន្ទុកដឹកនាំការងាររួម

២-ប្រគល់ភារកិច្ច លោកស្រី **ទឹម សំអាត** ជាអនុប្រធានផ្នែកគណនេយ្យអោយទទួលបន្ទុកដឹកនាំការងាររួម

៣-ប្រគល់ភារកិច្ច កញ្ញា **កែ មេនី** ជាបុគ្គលិកផ្នែករដ្ឋបាល អោយទទួលបន្ទុកដឹកនាំការងារ...

៤-បន្ទុយហ៊ាន: លោក **ហែម វណ្ណយុត្តិ** ពីប្រធានរតនាគារ មកជាបុគ្គលិក

៥-បន្ទុយហ៊ាន: លោកស្រី **យឹម និមល** ពីប្រធានផ្នែកគណនេយ្យមកជាបុគ្គលិក

៦-សិល្បការិកិច្ច កញ្ញា **លឹម ឡាទី** ដោយបញ្ឈប់ពីការងារគណនេយ្យករមកជាបុគ្គលិក

មាត្រា ២ : ករណីដោយឡែក ចំពោះមន្ត្រីរាជការចំនួន ០៣ នាក់ ខាងលើ :

១-លោក **ហែម វណ្ណយុត្តិ**

២-លោកស្រី **យឹម និមល**

៣-កញ្ញា **លឹម ឡាទី**

ដែលពាក់ព័ន្ធពីកំហុស និង ការភ្លាំភ្លងក្នុងវិជ្ជាជីវៈ ព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ដោយបានឃុបឃិតសមគំនិតលួចធ្វើបណ្ណដកឥណទានជាសាច់ប្រាក់ ចំនួន ៦២.០០០.០០០៛ (ហុកសិបពីរលានរៀលគត់) ខុសពីគោលការណ៍ ដែលប្រព្រឹត្តនៅ រតនាគារខេត្តក្រចេះ កាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៥ គឺអាស្រ័យដោយសមត្ថកិច្ច របស់អយ្យការអមតុលាការខេត្តក្រចេះធ្វើការចោទ ប្រកាន់ និង សំរេចវិនិច្ឆ័យទៅតាមនីតិវិធី ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧០ ចុះថ្ងៃ ទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

មាត្រា ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានថវិការដ្ឋ ប្រធាននាយកដ្ឋានវិនិយោគស្ថាបនាមូលដ្ឋាន ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងមាត្រា ០១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨១/៩៥ ព.ម.ក្រ.ប.

អនុញ្ញាតអោយសារពត៌មាន «នគរខ្មែរ» ដំណើរការបោះពុម្ពផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំបើកកាសែត «នគរខ្មែរ» របស់លោក **នូ គីមអ៊ី** ចុះថ្ងៃទី ០៧ ខែ កក្កដា ១៩៩៥

សម្រេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មាន «នគរខ្មែរ» ដំណើរការបោះពុម្ពផ្សាយ ដែលមានលោក **នូ គីមអ៊ី** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពង់ខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និង ស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់ រៀងរាល់លេខចេញផ្សាយមក តំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **នូ គឹមអ៊ី** ចាងហ្វាងកាសែត «នគរខ្មែរ» និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

១-សេចក្តីណែនាំ

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីណែនាំលេខ ០៥ សណន

ស្តីពីការអនុវត្តន៍ រៀបចំពិធីប្រឡង
ជ្រើសរើសបវរកញ្ញាកម្ពុជាប្រចាំ
ឆ្នាំ ១៩៩៦ នៃព្រះរាជាណាចក្រកម្ពុជា

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- អនុវត្តលិខិតលេខ ១១០៦ សជណ.អវ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

អនុវត្តតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចការពារ និង លើកតំកើងវិស័យ វប្បធម៌ខ្មែរអោយរីកចំរើន សុះសាយលើសកលលោក និង អនុវត្ត តាមទិសដៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្នុងការធ្វើអោយគំលៃ វប្បធម៌ខ្មែរ មានជីវិតស្វាហាប់ និង រស់ឡើងវិញ សំរាប់អោយសង្គមខ្មែរ ឈានទៅ រកភាពរឹងប៉ឹង និង រីកចំរើនក្នុងអនាគតដ៏ខ្លីខាងមុខនេះ ក្រសួងវប្បធម៌ និង វិចិត្រ សិល្បៈនឹងប្រារព្ធ ពិធីប្រឡងជ្រើសរើសបវរកញ្ញាឆ្នាំ ១៩៩៦ ប្រចាំព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២ និង ទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ នេះ នារោងមហោស្រពចតុមុខ ។

ពិធីប្រឡងជ្រើសរើសបវរកញ្ញាកម្ពុជាប្រចាំឆ្នាំ ១៩៩៦ គឺ ជាមធ្យោបាយមួយ ល្អប្រសើរ ក្នុងការលើកដំកើងវប្បធម៌ ដូចជា :

- ដើម្បីលើកតំកើងសោភ័ណភាពរបស់ស្ត្រីខ្មែរ ព្រមទាំងបង្ហាញជូនខ្មែរគ្រប់រូប និង អន្តរជាតិ អោយឃើញពីសំរស់របស់ស្ត្រីខ្មែរ គឺល្អបវរតាំងពីបុរាណកាល មក ។
- លើកស្ទួយនូវអត្តចរិត ជាប្រពៃណីដ៏ល្អរបស់ស្ត្រីខ្មែរ និង អប់រំអំពីបុគ្គលិកលក្ខណៈ ល្អប្រពៃសេចក្តីថ្លៃថ្នូរ និង សីលធម៌រស់នៅរបស់ស្ត្រីខ្មែរ ។
- ដើម្បីលើកតំកើង នូវភាពឆ្លាតវាងវៃ ខាងបញ្ញាស្មារតី បង្កើននូវសមត្ថភាពយល់ ដឹងទូលំទូលាយ ក្នុងសង្គម ។
- ដើម្បីបង្ហាញអំពីសំលៀកបំពាក់ នៃស្ត្រីខ្មែរក្នុងន័យអប់រំខ្មែរគ្រប់រូបអោយចេះ ស្រឡាញ់ ថែរក្សា ប្រពៃណី ទំនៀមទំលាប់ល្អប្រពៃដែលខ្មែរធ្លាប់មានតាំងពីបូរាណ ពិសេសអោយស្ត្រីខ្មែរចាប់អារម្មណ៍និយមចូលចិត្តប្រើប្រាស់សំលៀកបំពាក់ប្រពៃណី ខ្មែរ ។
- ជាឱកាសល្អដើម្បីសំដែងសិល្បៈល្អ ៗ ដែលជាស្នាដៃរបស់សិល្បៈករសិល្បៈការិនី ខ្មែរ ។
- ការប្រឡង គឺ ជាការផ្សព្វផ្សាយយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស ដើម្បីជាការ ឃោសនាទៅបរទេស អោយអន្តរជាតិមានការចាប់អារម្មណ៍អំពីវប្បធម៌ ទឹកដី និង មនុស្សខ្មែរ ពិសេសកិត្តិនាមដ៏ល្បី ល្បាញរបស់ស្ត្រីខ្មែរ លើឆាកអន្តរជាតិ ។

ដើម្បីអោយការប្រឡងជ្រើសរើសនេះ ប្រព្រឹត្តទៅដោយសុភវិនិច្ឆ័យ និង មានសកម្មភាពខ្ញូរខ្ញារ ក្នុងផ្ទៃប្រទេស ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សូមធ្វើការ ណែនាំជាក់ស្តែងមួយចំនួនដូចខាងក្រោមនេះ :

I–លក្ខណៈសម្បត្តិសុំចូលប្រឡង :

១–ការដាក់ពាក្យសុំ :

ក–ការប្រឡងជ្រើសរើសបវរកញ្ញាស្រុក ខ័ណ្ឌ និង កញ្ញាឯកក្រុមហ៊ុន សមាគម បេក្ខនារីត្រូវធ្វើពាក្យសុំចូលប្រឡង ដោយភ្ជាប់នូវ :

–សំបុត្រកំណើត	១ សន្លឹក
–ជីវប្រវត្តិសង្ខេប	១ សន្លឹក
–លិខិតបញ្ជាក់ទីលំនៅ	១ សន្លឹក
–រូបថត (៤ × ៦)	៤ សន្លឹក

ប្រគល់ជូនគណៈកម្មការប្រឡងជ្រើសរើសបវរកញ្ញា ស្រុកខ័ណ្ឌ និងក្រុមហ៊ុន សមាគម ដោយផ្ទាល់ដៃ ។

ខ–ការប្រឡងជ្រើសរើសបវរកញ្ញាខេត្ត–ក្រុង :

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ស្រុកខ័ណ្ឌ ធ្វើពាក្យសុំ បញ្ជូនបវរកញ្ញាស្រុកខ័ណ្ឌ ទៅគណៈកម្ម ការប្រឡងបវរកញ្ញាខេត្តក្រុង ដោយភ្ជាប់ជាមួយនូវ :

–របាយការណ៍ស្តីពីការប្រឡងបវរកញ្ញាខ័ណ្ឌស្រុក	២ សន្លឹក
–សេចក្តីប្រកាសរបស់គណៈកម្មការ ជាបវរកញ្ញាខ័ណ្ឌស្រុក	២ សន្លឹក
–សំបុត្រកំណើត	១ សន្លឹក
–ជីវប្រវត្តិសង្ខេប	១ សន្លឹក
–លិខិតបញ្ជាក់ទីលំនៅ	១ សន្លឹក
–រូបថត (៤ × ៦)	៤ សន្លឹក

គ–ការប្រឡងជ្រើសរើសបវរកញ្ញាប្រចាំព្រះរាជាណាចក្រកម្ពុជា :

មន្ទីរវប្បធម៌ខេត្តក្រុង ប្រធានក្រុមហ៊ុន និង សមាគម ដាក់ពាក្យសុំបញ្ជូនបវរកញ្ញាខេត្ត ក្រុង កញ្ញាឯកក្រុមហ៊ុន និង សមាគម មកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដោយភ្ជាប់មកជាមួយនូវ :

–របាយការណ៍ស្តីពីការប្រឡងបវរកញ្ញា កញ្ញាឯក	២ សន្លឹក
–សេចក្តីប្រកាសជាបវរកញ្ញា កញ្ញាឯក	២ សន្លឹក
–សំបុត្រកំណើត	១ សន្លឹក
–ជីវប្រវត្តិសង្ខេប	១ សន្លឹក

-លិខិតបញ្ជាក់ទីលំនៅ ១ សន្លឹក

-រូបថត (៤ × ៦) ៤ សន្លឹក

ដោយឡែកក្រុមហ៊ុន និង សមាគមត្រូវបន្ថែមលិខិតអនុញ្ញាតអោយធ្វើការប្រឡងកញ្ញាឯកជាមួយផង ។

២•ត្រូវមានសញ្ជាតិជាកម្ពុជា ត្រូវចេះអាន សរសេរ និង និយាយភាសាខ្មែរបានច្បាស់លាស់ល្អ ។

៣•ត្រូវនៅលីវ ប្រកបដោយសីលធម៌ល្អបរិសុទ្ធ មានអាយុពី ១៧ ឆ្នាំ ទៅ ២៧ ឆ្នាំ ត្រូវមានកំពស់ ពីមួយម៉ែត្រ ៦០ ឡើងទៅ ។

៤•ត្រូវមានរូបសម្បត្តិពីធម្មជាតិ គឺ មិនមានការវះកាត់កែសម្ផស្សឡើយ ។

៥•មិនធ្លាប់សំដែងក្នុងខ្សែភាពយន្ត វីដេអូ ឬ ល្ខោន និង មិនមែនបវរកញ្ញាកម្ពុជា ។

៦•ត្រូវមានសមត្ថភាពចំណេះដឹងទូទៅ អំពីវប្បធម៌ប្រវត្តិសាស្ត្រខ្មែរ ភូមិសាស្ត្រខ្មែរ និង វិជ្ជាមេផ្ទះ តាមប្រពៃណីខ្មែរ ។

៧•ត្រូវចេះរាំចង្វាក់ រាំវង់ រាំក្បាច់ តាមប្រពៃណីខ្មែរ និង ត្រូវចេះសូត្រកំណាព្យ ច្រៀងតាមបទ ប្រពៃណី ឬ ក្មេងសម័យដែលចេះចាំស្ទាត់ជាងគេ ។

II-**សំលៀកបំពាក់ពេលប្រឡង** :

១-ចងក្បិន តាមពិធីចំរើនព្រះជន្ម ក្នុងព្រះបរមរាជវាំង ។

២-ចោមពុងសារុង ក្រោមជង្គង់ ដោយមានកណ្សែ្បតក្លមផង ។

៣-សំលៀកបំពាក់មុជទឹក (សម័យ)

៤-សំលៀកបំពាក់ក្នុងពិធីជប់លៀងពេលល្ងាច (សម័យទំនើប) ។

៥-សំលៀកបំពាក់ជប់លៀងពេលល្ងាចតាមប្រពៃណីខ្មែរ (ផាមួង ឬ ចរបាប់)

III-**លក្ខណៈសម្បត្តិត្រូវជ្រើសរើសជាបវរកញ្ញា** :

ការរៀបចំពិធីប្រឡងជ្រើសរើសមានពីរដំណាក់កាល :

១-ដំណាក់កាលទី ១ : ការពិនិត្យសម្ផស្សខ្លួនប្រាណ

ក-កំពស់

-កំពស់ : ១,៦០ ស.ម ឡើង

-រង្វាស់ក្បាល : ១ ភាគ ៧ ឬ ១ ភាគ ៧ កន្លះនៃកំពស់

ខ–ផ្ទៃមុខ :

–រង្វង់មុខ គួរជាទីគយគន់នៃមនុស្សគ្រប់រូប

–ភ្នែកត្រង់បើកអស់ កែវភ្នែកភ្លឺថ្លា

–ថ្ពាល់រលោង

–រោមចិញ្ចើមកោងដូចផងធ្នូ

–ត្របកភ្នែក មានផ្នត់

–ច្រមុះសមនឹងរង្វង់មុខ

–បបូរមាត់ក្រាស សមល្មម

–ធ្មេញ សថ្លា ដូចភ្លុក (មិនមែនធ្មេញសិប្បនិមិត្ត)

គ–ស្បែក :

ស្បែកភ្លឺថ្លា គ្មានសំឡាក ឬ មានតិចតួច

ឃ–ដងខ្លួន :

–ដងខ្លួនស្ដើងល្មម សមនឹងកំពស់

–ដងខ្លួនទន់ភ្លន់ ល្វតល្វន់

–ទ្រូងពើងក្បំ

–ទ្រូងទំហំ ៨៤ សម ឬ ពី ៨២ ទៅ ៨៦ សម

–ចង្កេះទំហំ ៦១ សម ឬ ពី ៥៩ ទៅ ៦៣ សម

–ត្រគាកទំហំ ៩១ សម ឬ ពី ៨៩ ទៅ ៩៣ សម

ង–អវៈយវៈ

–ដៃស្រឡូន

–ម្រាមដៃទន់ស្រឡូនស្រួច

–ជើងស្រឡូន

–ប្រអប់ជើងសមនឹងម្រាមដូចស្និតចេក

២–ដំណាក់កាលទី ២ : ការពិនិត្យសម្រស់ជាមួយនឹងសំលៀកបំពាក់ សម្ពស្ស ដំណើរទន់ភ្លន់ ស្របតាមការតុបតែង

–សំលៀកបំពាក់ ជាម្ជុងចងក្បិន

–សារុងចោមពុង ដោយមានកណ្ដៀតក្អម

-សំលៀកបំពាក់ មុជទឹកសម័យ (អនុវត្តតែក្នុងការប្រឡងជ្រើសរើសបវរកញ្ញា ប្រចាំរាជធានីភ្នំពេញ និង ប្រចាំព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ)
-សំលៀកបំពាក់ ពិធីជប់លៀងពេលល្ងាច (សម័យ)
-សំលៀកបំពាក់ ពិធីជប់លៀងពេលល្ងាច តាមប្រពៃណីខ្មែរ
-ដំណើរតាមចង្វាក់ រាំវង់ រាំក្បាច់

៣-បទសំភាសន៍ផ្ទាល់ខ្លួន :
-បញ្ញាវៃឆ្លាតអាចឆ្លើយសំណួរបាន រហ័សនឹងត្រឹមត្រូវ ។
-សំលេងពិរោះ ពីធម្មជាតិ តាមរយៈចំលើយ ។
-បុគ្គលិកលក្ខណៈ សុភាព រាបសារ ក្លាហាន ថ្លៃថ្នូរ និង រួសរាយរាក់ទាក់ជា មិត្តភាព ។

IV-**ការអនុវត្តន៍** :

១-ការប្រឡងជ្រើសរើសបវរកញ្ញាប្រចាំព្រះរាជាណាចក្រកម្ពុជា
ការប្រឡងប្រព្រឹត្តទៅនៅរោងមហោស្រពចតុមុខរាជធានីភ្នំពេញ
-ថ្ងៃទី ២ វិច្ឆិកា ឆ្នាំ ១៩៩៥ ពិធីប្រឡងសម្ផស្សខ្លួនប្រាណ (អនុវត្តក្នុងជួរគណៈ មេប្រយោគ)។
-ថ្ងៃទី ៣ វិច្ឆិកា ឆ្នាំ ១៩៩៥ ពិធីប្រឡងសម្ផស្សជាមួយនឹងសំលៀកបំពាក់ រួមជាមួយនឹងបទ សំភាសន៍ ដើម្បីជ្រើសរើសបវរកញ្ញា ១ នាក់ កញ្ញាកិត្តិយសស្តាំ ១ នាក់ និង កញ្ញាកិត្តិយសឆ្វេង ១ នាក់ (ពិធីសាធារណៈ) ។

២-វិធានការអនុវត្ត ជាក់ស្តែងនៅតាមខេត្តក្រុង ក្រុមហ៊ុន និង សមាគម :

ក-មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ គ្រប់ខេត្តក្រុង ត្រូវសហការជាមួយអភិបាល ខេត្ត-ក្រុង រៀបចំ ជ្រើសរើសអោយបាននូវបវរកញ្ញាប្រចាំខេត្តក្រុង ក្នុងភូមិភាគ ក្របខ័ណ្ឌ របស់ខ្លួន ក្នុងនោះ ត្រូវធ្វើការប្រឡង ជ្រើសរើសអោយបានត្រឹមត្រូវ និង យុត្តិធម៌ នូវបវរកញ្ញាប្រចាំខេត្តក្រុង ១ នាក់ កញ្ញាកិត្តិយសស្តាំ ១ នាក់ និង ឆ្វេង ១ នាក់ ។ ខេត្តក្រុងនីមួយ ៗ គប្បីរៀបចំការប្រឡងជ្រើសរើសតាមស្រុក ខ័ណ្ឌនូវបវរកញ្ញា ១ នាក់ កញ្ញាកិត្តិយសអមស្តាំ ១ នាក់ និង អមឆ្វេង ១ នាក់ ប្រចាំស្រុកខ័ណ្ឌ ។ បវរកញ្ញាប្រចាំស្រុកខ័ណ្ឌនឹង ត្រូវបានអនុញ្ញាតអោយជាក់ វាក្យចូលប្រឡងជ្រើសរើសជាបវរកញ្ញា ជាកញ្ញាកិត្តិយសស្តាំ និង ជាកញ្ញា

កិត្តិយសឆ្នេងប្រចាំខេត្តក្រុង ។ ខេត្តក្រុងត្រូវធ្វើរបាយការណ៍ច្បាស់លាស់អំពីលទ្ធផលនៃការប្រឡង និង ដាក់ពាក្យសុំចូលប្រឡងជ្រើសរើសជាបវរកញ្ញាកម្ពុជាមកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈអោយបានមុន ថ្ងៃទី ១០ តុលា ឆ្នាំ ១៩៩៥។

ខ–ក្រុមហ៊ុន និង សមាគមនានា ដែលមានគំរោងជ្រើសរើស កញ្ញាឯកប្រចាំក្រុមហ៊ុន និង សមាគមរបស់ខ្លួន គប្បីដាក់ពាក្យសុំអនុញ្ញាតពីមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តក្រុង និង សាលាខេត្ត ក្រុង ដែលក្រុមហ៊ុន ឬ សមាគមនោះមានទីតាំងស្នាក់នៅ ។ ដោយឡែកនៅរាជធានីភ្នំពេញ ក្រុមហ៊ុន ឬ សមាគមត្រូវសុំអនុញ្ញាតដល់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ បន្ទាប់ពីបានការអនុញ្ញាតពីសាលាក្រុងភ្នំពេញ ។ ក្រោយពីការជ្រើសរើសបានកញ្ញាឯកប្រចាំក្រុមហ៊ុន ឬ សមាគមរួចហើយ ហើយមានបំណងចូលរួមក្នុង ការប្រកួតជ្រើសរើសបវរកញ្ញាកម្ពុជា ឆ្នាំ ១៩៩៦ ប្រចាំព្រះរាជាណាចក្រកម្ពុជា សូមដាក់ពាក្យសុំចូលប្រឡងមកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អោយបានមុនថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥ ។

គ–ការប្រឡងជ្រើសរើសក្នុងក្របខ័ណ្ឌ ខេត្តក្រុង តាមក្រុមហ៊ុន និង តាមសមាគម គប្បីយកចិត្តទុកដាក់អោយមានការសំដែងសិល្បៈ និង ការលើកដំកើងនូវវប្បធម៌ខ្មែរ ពិសេសត្រូវមានការតាំងពិព័រណ៍អំពី សមិទ្ធផលខាងវិស័យវប្បធម៌ និង វិចិត្រសិល្បៈ ក្នុងឆ្នាំ ១៩៩៥ នឹងមានគំរោងអភិវឌ្ឍន៍វប្បធម៌ឆ្នាំ ១៩៩៦ របស់ខេត្តក្រុង នីមួយ ៗ ។ ពិព័រណ៍របស់ខេត្តក្រុងនឹងត្រូវអនុញ្ញាតអោយតាំងនៅរាជធានីភ្នំពេញ ក្នុងឱកាសប្រឡងបវរកញ្ញាកម្ពុជា ឆ្នាំ ១៩៩៦ ។ ចំពោះការរៀបចំប្រឡងជ្រើសរើស គឺធ្វើពីរដំណាក់កាល :

–ពិនិត្យខ្នាតសម្ផស្សខ្លួនប្រាណ (ពិធីជាមួយតែក្រុមមេប្រយោគ) ដូចមានចែងក្នុងចំណុច ១ នៃ III ។

–ប្រឡងជ្រើសរើសសម្ផស្សជាមួយសំលៀកបំពាក់ ព្រមទាំងបទសំភាសន៍ (ពិធីជាសាធារណៈ) ដូចមាន ចែងក្នុងចំណុច ២ និង ៣ នៃ ៣ ។

ដោយឡែកស្រុកខ័ណ្ឌ របស់ខេត្តក្រុងទូទាំងប្រទេស (លើកលែងរាជធានីភ្នំពេញ) ត្រូវរៀបចំ ការប្រឡងជ្រើសរើសបវរកញ្ញាដោយអនុវត្តតែដំណាក់កាលទី១

គឺ ពិនិត្យខ្នាតសម្លេងខ្លួនប្រាណ រួចសំរាំង ជ្រើសរើសជាបវរកញ្ញា ជាកញ្ញាកិត្តិយសស្តាំ និង ជាកញ្ញាកិត្តិយសឆ្វេង ។

៣–ចំពោះបេក្ខនារីជាប់ចំណាត់ថ្នាក់ជាបវរកញ្ញា ប្រចាំខេត្តក្រុង និង បេក្ខនារីជាប់ចំណាត់ថ្នាក់ជា កញ្ញាឯកប្រចាំក្រុមហ៊ុន ឬ សមាគមត្រូវបានអនុញ្ញាតអោយចូលរួមប្រកួតជ្រើសរើសជាបវរកញ្ញាកម្ពុជា ជាកញ្ញាកិត្តិយសស្តាំ និង ជាកញ្ញាកិត្តិយសឆ្វេងប្រចាំឆ្នាំ ១៩៩៦ នៃព្រះរាជាណាចក្រកម្ពុជា ។

៤–ការដាក់ពាក្យសុំចូលប្រឡងជ្រើសរើសបវរកញ្ញា ឆ្នាំ ១៩៩៦ ប្រចាំព្រះរាជាណាចក្រកម្ពុជា នឹងផុតកំណត់ទទួលពាក្យនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥ វេលាម៉ោង ១៧.០០ ជាកំហិត នៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

៥–បវរកញ្ញាប្រចាំខេត្តក្រុង និង កញ្ញាឯកប្រចាំក្រុមហ៊ុន ឬ សមាគមត្រូវមកដល់រាជធានីភ្នំពេញ ជួបជុំគ្នានៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥ ជាកំហិតនៅទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សង្ឃឹមជឿជាក់ថា ឯកឧត្តម ប្រតិភូប្រចាំរាជធានីភ្នំពេញ ឯកឧត្តមអភិបាលខេត្តក្រុង លោកប្រធានមន្ទីរវប្បធម៌ គ្រប់ខេត្ត–ក្រុង លោកប្រធានក្រុមហ៊ុន លោកប្រធាន សមាគមនឹងរៀបចំអនុវត្តការងារ នេះអោយមានប្រសិទ្ធភាពប្រកបដោយសុភវិនិច្ឆ័យត្រឹមត្រូវ និង យុត្តិធម៌ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

២-ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៤៦ ប្រក
ស្តីពីការបង្កើតគណៈកម្មការកណ្តាល និង អនុគណៈកម្មការ ជំនួយការសំរាប់ការរៀបចំការប្រឡងជ្រើសរើស បវរកញ្ញា នៃព្រះរាជាណាចក្រកម្ពុជាប្រចាំឆ្នាំ ១៩៩៦

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា ធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១១០៦ សជណ អវ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការកណ្តាល និង អនុគណៈកម្មការជំនួយការមួយចំនួន សំរាប់ការរៀបចំប្រឡងជ្រើសរើសបវរកញ្ញានៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០២– ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ នារោងមហោស្រពចតុមុខ ។

ប្រការ ២ : សមាសភាព គណៈកម្មការកណ្តាលរួមមាន :

១–ឯកឧត្តម **នុត ណារ៉ាំង** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ប្រធាន

២–អ្នកអង្គម្ចាស់**ស៊ីសុវត្ថិ ស៊ីរិធរ ធំណារ៉ា** រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធានទទួលទំនាក់ទំនងសាធារណៈ

៣-សម្តេចរាជបុត្រីព្រះរៀម	**នរោត្តម បុប្ផាទេវី**	ទីប្រឹក្សារាជរដ្ឋាភិបាល	អនុប្រធានទទួលការងារផ្តល់ពិន្ទុ
៤-ឯកឧត្តម	**ម៉ែន យ៉េត**	អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	អនុប្រធានទទួលបច្ចេកទេស
៥-លោក	**ឈុម គួច**	ប្រធានអគ្គនាយកដ្ឋានរដ្ឋបាល	សមាជិកអចិន្ត្រៃយ៍
៦-លោក	**ពេជ ទុំក្រវិល**	ប្រធានអគ្គនាយកដ្ឋានបច្ចេកទេស	សមាជិកអចិន្ត្រៃយ៍
៧-លោក	**ស៊ឹម ស៊ាវ៉ាត់**	អ្នកទទួលខុសត្រូវនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌	សមាជិកអចិន្ត្រៃយ៍
៨-អ្នកស្រី	**ម៉ិញ គុសនី**		សមាជិកទទួលសំលៀកបំពាក់ បវរកញ្ញា និង បង្ហាត់កាយវិការ
៩-អ្នកស្រី	**ម៉ែន សាវ៉ៃ**		សមាជិកទទួលសំលៀកបំពាក់បវរកញ្ញា និង បង្ហាត់កាយវិការ
១០-លោក	**ឡុង ឧស្សឺ**	អគ្គនាយករងរដ្ឋបាលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិកទទួលការងារតែងនិពន្ធ និងសារពត៌មាន
១១-លោក	**ឌុយ ឡៀន**	ប្រតិភូសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	សមាជិកទទួលសិល្បៈ

១២–លោក	ហេង្ស សុត	អ្នកទទួលខុសត្រូវនាយកដ្ឋានសិល្បៈ	សមាជិកទទួលសិល្បៈ
១៣–លោក	ប្រាក់ ឃ្លួយ	ប្រធាននាយកដ្ឋានផែនការ	សមាជិកថវិកា ពិធីការ
១៤–លោក	ផាន់ សាអ៊ាត់	អ្នកទទួលខុសត្រូវនាយកដ្ឋានរដ្ឋបាលសំណុំលិខិត	សមាជិក
១៥–លោក	ជុច តៀន	អ្នកទទួលខុសត្រូវនាយកដ្ឋានបេតិកភ័ណ្ឌ	សមាជិក ខាតសម្ភស្ស
១៦–លោក	ដែក សារិន	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌	សមាជិក ពិព័រណ៍តុបតែង និង ផ្សារណាត់
១៧–លោក	ចាន់ សន	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌	សមាជិក ទទួលការប្រឡងតាមខេត្តក្រុង
១៨–លោក	មាស អ៊ាន់ឡើន	ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ	សមាជិកទទួលខុសត្រូវការអំពាវនាវរកជំនួយ
១៩–លោក	យឹម សារិត	អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ	សមាជិកទទួលសន្តិសុខសណ្តាប់ធ្នាប់
២០–កញ្ញា	ហាក់ ស្រីមុំ	បវរកញ្ញាលេខ ១ កម្ពុជាឆ្នាំ ១៩៩៣	សមាជិកទំនាក់ទំនងសាធារណៈ

ប្រការ ៣ : គណៈកម្មការនេះមានភារកិច្ច :

– រៀបចំការប្រឡងជ្រើសរើសបវរកញ្ញាជាតិប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

- អំពាវនាវសប្បុរសជន ចូលរួមជួយឧបត្ថម្ភជាសំភារៈជាថវិកា សំរាប់ជូនជារង្វាន់ និង លើកទឹកចិត្តដល់ជ័យលាភីក្នុងការប្រឡង ។
- អញ្ជើញគ្រប់សមាជិកសមាជិកា ចូលរួមប្រជុំគ្រប់កាលៈទេសៈដ៏ចាំបាច់ ។
- គ្រប់គ្រងអប់រំឧបត្ថម្ភផ្នែកសីលធម៌របស់បវរកញ្ញាកម្ពុជា អោយបានតាមក្រឹត្យក្រម ។
- មានសិទ្ធិអនុញ្ញាតណែនាំខ្លឹមសារ រូបភាព បច្ចេកទេស និង ត្រួតពិនិត្យរាល់ការរៀបចំ ប្រឡងជ្រើសរើសបវរកញ្ញាតាមខេត្តក្រុង និង កញ្ញាឯកកាមបណ្ដាក្រុមហ៊ុន សមាគម នានា ។

ប្រការ ៤ : អនុគណៈកម្មការជំនួយការរួមមាន :

ក–លេខាធិការដ្ឋានអចិន្ត្រៃយ៍មានភារកិច្ច :

–តែងសន្ទរកថា « បើកបិទ »
–ធ្វើបទពណ៌នាក្នុងពិធី
–រៀបចំកម្មវិធី
–បទបញ្ជាផ្ទៃក្នុង
–កិច្ចសន្យា
–ធ្វើសំណួរចម្លើយ
–កំណត់ហេតុ
–របាយការណ៍
–ថតរូប និង ភាពយន្តវីដេអូ
–ទទួលខុសត្រូវអ្នកសារពត៌មាន
–ទទួលការបោះពុម្ព
–ទទួលពាក្យសុំ និង សំរេចជាបេក្ខជនបវរកញ្ញាកម្ពុជា

សមាសភាពក្នុងលេខាធិការដ្ឋានរួមមាន :

១–លោក	**ស៊ឹម សាវ៉ាត**	ប្រធាន
២–លោក	**ឡុង ឌុល្លី**	អនុប្រធាន
៣–លោក	**ឆាន់ សាវ៉ាត់**	អនុប្រធាន
៤–លោក	**អ៊ីន ស៊ីយន្តា**	អនុប្រធាន
៥–លោក	**មាស សារុន**	សមាជិក

៦–លោក	សេង សែ	សមាជិក
៧–លោក	អាំ ទុន្លា	សមាជិក
៨–កញ្ញា	ទួន ទិធារី	សមាជិក
៩–លោក	នូ សោភ័ណ	សមាជិក
១០–លោក	យូ សាទុត	សមាជិក
១១–លោក	យឹម សិរីរេល	សមាជិក
១២–អ្នកស្រី	ភ្នំ សុគី	សមាជិក
១៣–អ្នកស្រី	ឈន់ សាឌី	សមាជិក
១៤–លោក	ឃ្លោក សារុន	សមាជិក
១៥–លោក	អ៊ុម សុធារិទ្ធិ	សមាជិក
១៦–លោក	ឌឹម ឈាំ	សមាជិក

ខ–អនុគណៈកម្មការទំនាក់ទំនងសាធារណៈមានភារកិច្ច :

–ធ្វើការឃោសនា
–អំពាវនាវសុំជំនួយឧបត្ថម្ភ
–ពិធីការ លិខិតអញ្ជើញ ទទួលភ្ញៀវជាតិ អន្តរជាតិ
–បរិភោគសុជ្ជៈ
–រៀបចំកន្លែងអង្គុយ

សមាសភាពអនុគណៈកម្មការនេះរួមមាន :

១–លោក	មាស ទ៉ាន់ហ្វៀន	ប្រធាន
២–អ្នកស្រី	គីន សំមោច	អនុប្រធាន
៣–លោក	ឆាន់ សាទ៉ាត់	អនុប្រធាន
៤–លោក	ជែក សារិន	អនុប្រធាន
៥–លោក	និល សាអ៊ុន	អចិន្ត្រៃយ៍
៦–អ្នកស្រី	ម៉ុត សុផាត	សមាជិក
៧–លោក	សួស ផុន	សមាជិក

៨-លោក	គីម គុណសោ	សមាជិក
៩-អ្នកស្រី	លន់ សាឌី	សមាជិក
១០-អ្នកស្រី	ហ៊ឹម ណារ៉ា	សមាជិក

គ-អនុគណៈកម្មការថវិកាហិរញ្ញកិច្ច មានភារកិច្ច :

-ដោះស្រាយថវិកា

-ទទួលដោះស្រាយសំភារៈ

-លក់សំបុត្រ

-ទទួលការស្នាក់នៅ ម្ហូបអាហារបវរកញ្ញាមកពីខេត្ត ក្រុង ក្រុមហ៊ុន សមាគម

-មធ្យោបាយដឹកនាំ

សមាសភាពអនុគណៈកម្មការនេះរួមមាន :

១-លោក	ណុម គួច	ប្រធាន
២-លោក	ច្រាក់ ឡួយ	អនុប្រធាន
៣-លោក	ដែក សារិន	អនុប្រធាន
៤-លោក	មាស សារុន	អនុប្រធាន
៥-លោក	ពេជ ណន	សមាជិក
៦-លោក	ឃ្លោក សារុន	សមាជិក
៧-អ្នកស្រី	លន់ សាឌី	សមាជិក
៨-អ្នកស្រី	ឈួន ណារី	សមាជិក
៩-អ្នកស្រី	អ៊ុន កែវដាន់ណា	សមាជិក
១០-អ្នកស្រី	ម៉ែន សំអ៊ន	សមាជិក

ឃ-អនុគណៈកម្មការបច្ចេកទេស មានភារកិច្ចរៀបចំ :

-ទីកន្លែងប្រឡងជ្រើសរើសបវរកញ្ញា

-បង្ហាត់ និង ណែនាំបវរកញ្ញាសំរាប់ប្រឡង

-តុបតែងលំអឆាក

-បំភ្លឺភ្លើង

-វង់តន្ត្រី និង សិល្បៈកំដរ

-បញ្ហាអគ្គិសនី

សមាសភាពអនុគណៈកម្មការនេះរួមមាន :

១-លោក	ហង្ស សុត	ប្រធាន
២-លោក	ជែត សារិន	អនុប្រធាន
៣-លោក	ឡោ សាន	អនុប្រធាន
៤-លោក	ទែន ផាត	សមាជិក
៥-លោក	ភ្លៀង ឈៀង	សមាជិក
៦-លោក	ម៉ៅ គេង	សមាជិក
៧-លោក	ឯល ប៊ុណ្ណា	សមាជិក
៨-លោក	ហង្ស សុវណ្ណ	សមាជិក
៩-លោក	ជា សុវណ្ណា	សមាជិក
១០-លោក	ទ៉ាន់ ផេន	សមាជិក
១១-អ្នកស្រី	នន ចន្ថន	សមាជិក
១២-អ្នកស្រី	ឯម ឆាយ	សមាជិក
១៣-អ្នកស្រី	ម៉ិញ គុសនី	សមាជិក
១៤-អ្នកស្រី	រ៉ែន សារ៉ែ	សមាជិក
១៥-លោក	ហ៊ុន សារិន	សមាជិក

ង-អនុគណៈកម្មការសន្តិសុខសណ្តាប់ធ្នាប់មានភារកិច្ច :

-ការពារសុវត្ថិភាពពេលប្រារព្ធពិធី

-សណ្តាប់ធ្នាប់ការចតរថយន្ត

-ត្រូវមានភ្នាក់ងារសុខាភិបាល

-ត្រូវមានភ្នាក់ងាររថយន្តអគ្គីភ័យ

សមាសភាពអនុគណៈកម្មការនេះរួមមាន :

១-លោក	យឹម សារិត	ប្រធាន
២-លោក	នុយ ស៊ីថា	អនុប្រធាន

៣–លោក ហង្ស សុវណ្ណ អនុប្រធាន
៤–លោក ជា សុវណ្ណា សមាជិក
៥–លោក រួន ឡូនៅអ៊ា សមាជិក
៦–លោក អន សារឿន សមាជិក
៧–លោក ឿន សារេត សមាជិក
៨–លោក សន មាន សមាជិក
៩–លោក ហ៊ុយ ឆារៈ សមាជិក
១០–លោក រស់ ចំរើន សមាជិក

ច–អនុគណៈកម្មការទទួលបន្ទុកការងារជ្រើសរើសបវរកញ្ញាខេត្ត ក្រុង និង កញ្ញាឯកក្រុមហ៊ុន និង សមាគម មានភារកិច្ច :

– អនុញ្ញាត និង ណែនាំ ត្រួតពិនិត្យផ្ទាល់ការប្រឡងជ្រើសរើសបវរកញ្ញាតាមខេត្ត–ក្រុង និង កញ្ញាឯកតាមក្រុមហ៊ុន និង សមាគម ។
– មានសិទ្ធិចូលរួមក្នុងសមាសភាពគណៈកម្មការជ្រើសរើសបវរកញ្ញា ខេត្ត–ក្រុង និង កញ្ញា ឯកក្រុមហ៊ុន សមាគម ។

សមាសភាពអនុគណៈកម្មការនេះរួមមាន :

១–លោក ពេជ្រ ទុំក្រវិល ប្រធាន
២–លោក ឃួន ថន អនុប្រធាន
៣–លោក ស៊ឹម សារ៉ាក់ សមាជិក
៤–លោក ចាន់ សន សមាជិក
៥–លោក ជែត សារិន សមាជិក
៦–លោក ហង្ស សុត សមាជិក
៧–លោក ម៉ៅ គេង សមាជិក
៨–អ្នកស្រី ម៉ុញ្ញ កុសល់ សមាជិក
៩–លោក ទ៉ាន់ ផេង សមាជិក
១០–លោក នឹម ណសាំ សមាជិក

១១–លោក ឡិក សារុំ សមាជិក

ប្រការ ៥ : អនុគណៈកម្មការនីមួយ ៗ ត្រូវទទួលខុសត្រូវចំពោះមុខគណៈកម្មការកណ្ដាល និង អាចមានសិទ្ធិជ្រើសរើសមន្ត្រីរាជការបន្ថែមក្នុងអង្គភាពដែលពាក់ព័ន្ធបែងចែកភារកិច្ច លំអិតថែមទៀត ដើម្បីសំរេចភារកិច្ច ។

រដ្ឋមន្ត្រី

ហិរញ្ញវត្ថុ និង ព្រា

នុត ណារ៉ាង

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៧ ប្រក.វវស.ប្

ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ មន្ទីរ

វប្បធម៌ និង វិចិត្រសិល្បៈខេត្តស្វាយរៀង

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំលុបឈ្មោះលេខ ១៥ បត.វវស.សរ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : មន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តស្វាយរៀងចំនួន ០២ «ពីរ» នាក់ ដូច មានរាយនាមខាងក្រោមនេះ ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌ

មន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តស្វាយរៀងចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៥ ដោយបោះបង់ចោលការងារ ÷

១-លោក **សោម អ៊ុស** បុគ្គលិកការិយាល័យសិល្បៈ

២-កញ្ញា **ពៅ សុម៉ាលី** បុគ្គលិកការិយាល័យសិល្បៈ

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តស្វាយរៀង ព្រមទាំងសាមី ខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខានិងត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ប៉ាណារ៉ា

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៨ ប្រក.វបស.មុ

ស្តីពីការផ្អាកការងារមួយរយៈដោយពុំទទួលបៀវត្ស

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសារាចរណែនាំលេខ ០៣ សរ ចុះថ្ងៃទី ០៥ មីនា ឆ្នាំ ១៩៩៣ ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការ ស៊ីវិល ផ្អាកការងារមួយរយៈដោយគ្មានបៀវត្សប្រចាំខែ
- យោងតាមសំណើសុំរបស់អ្នកស្រី **គាន រដ្ឋា** បុគ្គលិកនៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៥
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយឈប់សំរាកផ្អាកការងារចំនួន ០១ ឆ្នាំ ដល់អ្នកស្រី **គាង វឌ្ឍា** បុគ្គលិក នៃមន្ទីរ វប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញដោយគ្មានបៀវត្សនិងស្នើសុំរក្សាទុកក្របខ័ណ្ឌ ដដែលដោយគិតចាប់ ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : បៀវត្សប្រចាំខែនិងរាល់ផលប្រយោជន៍របស់អ្នកស្រី **គាង វឌ្ឍា** ត្រូវផ្អាកលែងអោយ បើកចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ តទៅរហូតដល់មានលិខិតអនុញ្ញាតអោយចូលបំរើការងារពីក្រសួងវិញ ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ និង អ្នកស្រី **គាង វឌ្ឍា** ត្រូវអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ៨ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៨២ សក-អជជ-តពយ

ស្តីពីការធ្វើអាជីវកម្មសាលាបង្រៀនបើកបររថយន្ត

* * *

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញរាជក្រឹត្យ លេខ នស–រកត–១០៩៤–៩០ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកំណត់ហេតុប្រជុំ ថ្ងៃទី ១៤–០១–១៩៩៥ អំពីការពង្រឹងសាលាបង្រៀនបើកបររថយន្ត អោយមានដំណើរប្រព្រឹត្តទៅបានកាន់តែល្អប្រសើរថែមទៀត
- ដោយផ្អែកតាមសំណូមពររបស់អគ្គនាយកដ្ឋានដឹកជញ្ជូន

សម្រេច

ប្រការ ១ : ការធ្វើអាជីវកម្មសាលាបង្រៀនបើកបររថយន្ត និង ទោចក្រយានយន្ត ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ប្រការ ២ : ម្ចាស់គ្រឹះស្ថានសិក្សាត្រូវដាក់ពាក្យសុំធ្វើអាជីវកម្មសាលាបង្រៀនបើកបររថយន្ត ឬបង្រៀនបើកបរទោចក្រយានយន្ត នៅក្រសួងសាធារណការ និងដឹកជញ្ជូន តាមរយៈរដ្ឋអំណាចខេត្ត–ក្រុង ហើយ ត្រូវមានឯកសារភ្ជាប់មកជាមួយដូចខាងក្រោម :

១–បញ្ជីជាតិ	១ ច្បាប់
២–រូបថត បីគុណនឹងបួន	៣ សន្លឹក
៣–លិខិតបញ្ជាក់កម្មសិទ្ធិ ឬកិច្ចសន្យាជួលទីស្នាក់ការសាលា	១ ច្បាប់
៤–ផែនទី ទីស្នាក់ការសាលា និងអាស័យដ្ឋាន	១ ច្បាប់
៥–លិខិតធានារ៉ាប់រងលើរថយន្តសំរាប់បង្រៀន ក្នុងរថយន្តមួយគ្រឿង	១ ច្បាប់
៦–ឈ្មោះ និងលិខិតបញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់	១ ច្បាប់
បើសិនជាម្ចាស់សាលាជានីតិបុគ្គល ត្រូវមានបន្ថែមនូវ :	
៧–លក្ខន្តិកៈរបស់ក្រុមហ៊ុន	១ ច្បាប់
៨–លិខិតតែងតាំងប្រធានក្រុមហ៊ុន	១ ច្បាប់

ប្រការ ៣ : ក្នុងករណី ដែលអាជីវករមានបំណងបើកសាខាសាលាបង្រៀនបើកបរបន្ថែមទៀត អាជីវករត្រូវដាក់ ពាក្យស្នើសុំតាមបែបបទដូចមានចែងក្នុងប្រការ ២ ។

ប្រការ ៤ : លិខិតបញ្ជាក់សមត្ថភាពគ្រូបង្ហាត់ :

អាជីវករត្រូវបង្ហាត់បង្រៀនតែប្រភេទយានយន្តណា ដែលមានកំណត់នៅក្នុងលិខិតអនុញ្ញាត និងប្រើប្រាស់តែគ្រូ បង្ហាត់ណាដែលបានប្រឡងជាប់ក្នុងការបង្ហាត់បង្រៀន

និងមាន លិខិតបញ្ជាក់សមត្ថភាព ដែលចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ប្រការ ៥ : ទីស្នាក់ការសាលា : ទីស្នាក់ត្រូវចែកជាពីរបន្ទប់ គឺ : បន្ទប់សំរាប់ទទួលចុះឈ្មោះសិស្ស និងបន្ទប់សំរាប់បង្ហាត់ផ្នែកទ្រឹស្តី ។ បន្ទប់ទាំងពីរនេះត្រូវមានច្រក ចេញ–ចូលដាច់ដោយឡែកពីគ្នា និងត្រូវរៀបចំយ៉ាងណា កុំអោយមានសំឡេងរំខានដល់សិស្សដែលកំពុងរៀន ។

ក្នុងបន្ទប់ទទួលចុះឈ្មោះសិស្សត្រូវមានបិទផ្សាយ :

១–លិខិតអនុញ្ញាតអោយធ្វើអាជីវកម្ម

២–ឈ្មោះប្រធានសាលា និងគ្រូបង្ហាត់

៣–តំលៃសិក្សា

ប្រការ ៦ : រយៈពេលធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស : យានយន្តដែលប្រើប្រាស់សំរាប់បង្រៀនបើកបរត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស តាមរយៈពេលដូចខាងក្រោម :

- ៦ ខែ ម្តងចំពោះរថយន្តដឹកទេសចរណ៍ ដែលមានទម្ងន់បន្ទុកអនុញ្ញាតសរុបតិចជាង ៣៥០០ គក្រ
- ៦ ខែ ម្តងចំពោះរថយន្តដុនធំដឹកអ្នកដំណើរ
- មួយឆ្នាំម្តងចំពោះរថយន្តដុនធំដឹកទំនិញ
- មួយឆ្នាំម្តងចំពោះទោចក្រយានយន្ត ។

ប្រការ ៧ : លក្ខណៈបច្ចេកទេសនៃយានយន្ត និងផ្លាកសញ្ញា : ចំពោះរថយន្តដែលប្រើប្រាស់សំរាប់បង្រៀនសិស្សសាលាបើកបរត្រូវមាន :

១–ប្រព័ន្ធបញ្ជាហ្វ្រាំងជើងចំនួនពីរ

២–ប្រព័ន្ធបញ្ជាអំប្រាយ៉ាចំនួនពីរ ។ ប្រព័ន្ធបញ្ជាហ្វ្រាំង និងប្រព័ន្ធបញ្ជាអំប្រាយ៉ាត្រូវរៀបចំ យ៉ាងណាអោយគ្រូបង្ហាត់អាចចាប់ហ្វ្រាំង ឬ ផ្តាច់អំប្រាយ៉ាបានយ៉ាងឆាប់រហ័សនៅពេល ដែលសិស្សមានការខុសឆ្គង ឬ ភ្ញាក់ភ្ញាក់ក្នុងករណីណាមួយ ។

៣–កញ្ចក់មើលក្រោយនៅខាងក្នុងពីរ និង កញ្ចក់មើលក្រោយនៅសងខាងពីរគូ។ ទាំងកញ្ចក់ ក្នុងនិងក្រៅត្រូវដាក់មួយផ្នែកសំរាប់គ្រូបង្ហាត់មើល និង មួយផ្នែកទៀតសំរាប់សិស្សមើល ។

៤–ផ្លាកអក្សរ « រៀនបើកបរ » សំរាប់ :

ក-រថយន្តធុនតូច : ត្រូវសរសេរអក្សរ «រៀនបើកបរ » នៅក្នុងផ្លាកពណ៌ខៀវ ទឹកប៊ិចទំហំ ៧០ គុណ ១៤ ស.ម ។ អក្សរ «រៀនបើកបរ » ត្រូវសរសេរជាអក្សរមូលពណ៌ស កំពស់ ៦ ស.ម កម្រាស់ ១,៥ស.ម និង មានសញ្ញាត្រីកោណសម័ង្សពីរ អមសងខាងមានកំពស់ ៨ ស.ម ។ ផ្លាកនេះត្រូវសរសេរទាំងសងខាងដាក់នៅលើដំបូលរថយន្ត ដើម្បីអោយគេ មើលពីខាងមុខនិងខាងក្រោយឃើញច្បាស់ និង មានពន្លឺបញ្ចាំងនៅពេលយប់ «រូបទី ១» ។ ចំពោះរថយន្ត មីនីប៊ីស ត្រូវដាក់បន្ថែមនូវផ្លាក ៤ជ្រុង ពណ៌ខៀវទឹកប៊ិច ទំហំ ៣០ គុណ ៣០ ស.ម ពីរទៀត ។

នៅក្នុងផ្លាក ៤ជ្រុងនេះ មានសញ្ញាត្រីកោណសម័ង្សពណ៌លឿងមួយ កំពស់ ២០ ស.ម នៅចំកណ្តាល នៅក្នុង ត្រីកោណនេះ មានសរសេរអក្សរ «រៀនបើកបរ» ពណ៌ខ្មៅ កំពស់ ២ ស.ម និងកំរាស់ ០,៤សម «រូបទី២» ដាក់នៅខាងក្រោយរថយន្តខាងស្តាំមួយ និងឆ្វេងមួយ ។

ខ-រថយន្តធុនធំ : ត្រូវមានសញ្ញាដូចគ្នា នឹងរថយន្តធុនតូចដែរ ប៉ុន្តែទំហំផ្លាកគឺ ១០០ គុណ២០ ស.ម ។ អក្សរ «រៀនបើកបរ» មានកំពស់ ១០ ស.ម កម្រាស់អក្សរ ២ ស.ម រីឯ កំពស់ត្រីកោណ ១២ ស.ម ។ ផ្លាកនេះត្រូវដាក់នៅកាប៊ីនខាងមុខ និងមានសញ្ញាត្រីកោណ សម័ង្សពីរ «រូបទី៣» ដាក់នៅខាងក្រោយរថយន្តផ្នែកខាងស្តាំមួយខាងឆ្វេងមួយ ។

គ-ម៉ូតូកង់យានយន្ត : នៅពេលកំពុងរៀន អ្នកបើកបរត្រូវពាក់អាវអៀមពណ៌ខៀវទឹក ប៊ិចដែលមានសញ្ញាត្រីកោណ សម័ង្សពណ៌លឿងកំពស់ ២០ស.ម នៅចំកណ្តាលខាងមុខ និង ខាងក្រោយ ។ នៅក្នុងសញ្ញាត្រីកោណនេះ ត្រូវសរសេរអក្សរ «រៀនបើកបរ» ជាអក្សរ មូលពណ៌ខ្មៅកំពស់ ១ ស.ម និង កំរាស់ ០,៤ ស.ម «រូបទី ៤» ។ គ្រូបង្ហាត់ត្រូវជិះពីក្រោយ ហើយពាក់អាវអៀមដូចគ្នានេះដែរ ។

ឃ-យានយន្តទាំងឡាយដែលធ្វើចរាចរនៅលើផ្លូវសាធារណៈ បើសិនជាឃើញយាន យន្តដែលមានសញ្ញាដូចមាន រៀបរាប់ខាងលើនេះ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ជាពិសេស មិនត្រូវបើកនៅជិតយានយន្តដែល កំពុងរៀនបើកបរឡើយ ។

៥-នៅសងខាងរថយន្តត្រូវមានសរសេរឈ្មោះសាលាបង្រៀនបើកបរ ។ អក្សរពណ៌ស ឬ ខ្មៅ មានកំពស់ ១៥ ស.ម កំរាស់ ៣ ស.ម ។

ប្រការ ៨ : រថយន្តសំរាប់បង្ហាត់បង្រៀនសិស្ស ត្រូវមានលិខិតធានារ៉ាប់រងគ្រប់ករណីគ្រោះថ្នាក់ទាំងអស់ (assurance tout risque) ទោះជាគ្រោះថ្នាក់នេះធ្លាក់ទៅលើអ្នកដទៃ ឬអ្នកដែលជិះនៅក្នុងរថយន្តក៏ដោយ ។

ប្រការ ៩ : កម្មវិធីសិក្សា :

សាលាបង្រៀនបើកបរត្រូវបង្រៀនសិស្សតាមកម្មវិធីដូចខាងក្រោម :

ក-រថយន្តទូរទេសចរណ៍ :

- ផ្នែកទ្រឹស្តី ច្បាប់ចរាចរផ្លូវគោក ៤០ ម៉ោង
- ផ្នែកអនុវត្តដៃចង្កូត នៅលើផ្លូវសាធារណៈ ៥០ ម៉ោង
- ផ្នែកបច្ចេកទេសរថយន្ត ១០ ម៉ោង
- ផ្នែកយល់ដឹងសង្គ្រោះបន្ទាន់ ៦ ម៉ោង

ខ-រថយន្តដឹកអ្នកដំណើរធុនធំ :

- ផ្នែកទ្រឹស្តី : ច្បាប់ចរាចរផ្លូវគោក ៤០ ម៉ោង
- ផ្នែកអនុវត្តដៃចង្កូត នៅលើផ្លូវសាធារណៈ ៦០ ម៉ោង
- ផ្នែកបច្ចេកទេសរថយន្ត ១០ ម៉ោង
- ផ្នែកយល់ដឹងការពារអ្នកដំណើរ ២ ម៉ោង
- ផ្នែកយល់ដឹងការសង្គ្រោះបន្ទាន់ ៦ ម៉ោង

គ-រថយន្តដឹកទំនិញ :

- ផ្នែកទ្រឹស្តី : ច្បាប់ចរាចរផ្លូវគោក ៤០ ម៉ោង
- ផ្នែកអនុវត្តជាក់ស្តែង នៅលើផ្លូវសាធារណៈ ៦០ ម៉ោង
- ផ្នែកបច្ចេកទេសរថយន្ត ១០ ម៉ោង
- ការផ្ទុក និងការលើកដាក់ ២ ម៉ោង

-ផ្នែកយល់ដឹងការសង្គ្រោះបន្ទាន់ ៦ ម៉ោង

ខ-សៀវភៅ និងឯកសារដែលត្រូវយកមកបង្រៀនសិស្សគឺ :

- ច្បាប់ចរាចរផ្លូវគោក « នៅពេលដែលរដ្ឋសភាបានអនុម័តរួច »
- អ្វីដែលអ្នកបើកបរត្រូវយល់ដឹង
- ចំពោះការយល់ដឹងសង្គ្រោះបន្ទាន់ ត្រូវអញ្ជើញអ្នកបច្ចេកទេសសង្គ្រោះបន្ទាន់នៅក្រសួងសុខាភិបាលមកបង្រៀន តាមរយៈពេលកំណត់
- សារាចរផ្សេងៗដែលទាក់ទងដល់ការងារចរាចរ និងដឹកជញ្ជូន
- ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានដឹកជញ្ជូន អាចធ្វើការកែប្រែកម្មវិធីសិក្សានេះបាន ដើម្បីធានាការយល់ដឹង អោយមានកំរិតកាន់តែខ្ពស់ថែមទៀត ។

ប្រការ ១០: គណៈកម្មការត្រួតពិនិត្យសាលា ត្រូវចុះត្រួតពិនិត្យបរិដ្ឋាននៃទីស្នាក់ការ និង ការបង្ហាត់បង្រៀនសិស្សដើម្បីធានាអោយដឹងថាអ្វីៗប្រព្រឹត្តទៅបានល្អដូចដែលមានចែងនៅក្នុងប្រកាសនេះ ។

ប្រការ ១១: លោកអគ្គនាយកនៃក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អ៊ឹង គៀត

* * *

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៤២៨ ប.ស្ត

ស្តីពីការផ្ទេរភារកិច្ចជូនមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិដ្ឋាន

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ។

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត ១០-៩៤.៨៣ ចុះថ្ងៃទី ២៤-១០-១៩៩៤ ។
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ១៩៩៤ ដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- យោងការស្នើសុំរបស់សាមីខ្លួន ចុះថ្ងៃទី ១១ កក្កដា ១៩៩៥ ។
- ពិនិត្យលើការចាំបាច់របស់មន្ទីរ គ្រប់គ្រងបរិស្ថាន ក្រុងព្រះសីហនុ ។

សម្រេច

ប្រការ ១ : ផ្ទេរភារកិច្ចជូន លោក **ជា ស៊ីណា** ជាមន្ត្រីរាជការបំរើការងារនៅ នាយកដ្ឋានត្រួតពិនិត្យទប់ស្កាត់ និង បន្ថយការបំពុលបរិស្ថាន អោយទៅបំរើការងារនៅមន្ទីរគ្រប់គ្រងបរិស្ថាន ក្រុងព្រះសីហនុ ។

ប្រការ ២ : ប្រាក់បៀវត្ស និង របបឧបត្ថម្ភផ្សេងៗមន្ទីរគ្រប់គ្រងបរិស្ថានជានាផ្គត់ផ្គង់បន្ត បន្ទាប់ពីមានវិញ្ញាបនប័ត្រផ្តាច់ប្រាក់ពីអង្គភាពដើម ។

ប្រការ ៣ : អគ្គនាយក ខុទ្ទកាល័យ អង្គភាពដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត **ម៉ុក ម៉ារ៉េត**

* * *

៦-ទីស្តីការ ក្រសួងធម្មការ និង សាសនា

ប្រកាស

ភ្នំពេញ ,ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៦៦/៩៥ កធស.ប្រក

ស្តីពីការទទួលស្គាល់មន្ត្រីរាជការក្នុង

ក្របខ័ណ្ឌ ក្រសួងធម្មការ និង សាសនា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៨២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
- បានឃើញលិខិតលេខ ៧០១ អយក–ប្រក ចុះថ្ងៃទី ១៩ កក្កដា ១៩៩៥ របស់ក្រសួងអប់រំយុវ ជន និង កីឡា

សម្រេច

ប្រការ ១ : យល់ព្រមទទួលស្គាល់ភិក្ខុ **ឈឹ សំបូរ** គ្រូមធ្យមកំរិត ១ ផ្នែកអក្សរសាស្ត្រចូលក្នុងក្របខ័ណ្ឌ ក្រសួង ធម្មការ និងសាសនា ក្នុងការសាកល្បង ។

ប្រការ ២ : ភិក្ខុ **ឈឹ សំបូរ** ត្រូវចាត់តាំងអោយទៅបង្រៀននៅ វិទ្យាល័យព្រះសុរាម្រិត ជាគ្រូកំរិត ១ ផ្នែកអក្សរសាស្ត្រ ។

ប្រការ ៣ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់ ភិក្ខុ **ឈឹ សំបូរ** គិតចាប់ពីថ្ងៃទី ០១ សីហា ១៩៩៥ តទៅ ។

ប្រការ ៤ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ច អគ្គាធិការដ្ឋានពុទ្ធិកសិក្សា វិទ្យាល័យព្រះសុរាម្រិត និង ភិក្ខុ **ឈឹ សំបូរ** ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះរៀងៗខ្លួន ។

ប្រការ ៥ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់តាំងពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហឿន ខណ្ណរ័ត្ន

* * *

ភ្នំពេញ ,ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧/៩៥ កធស.ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការក្នុង

ក្របខ័ណ្ឌ ក្រសួងធម្មការ និង សាសនា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យសុំផ្លាស់របស់លោក **ជេត ញ៉ឺន** ,លោក **អ៊ុំ ស៊ុម** ចុះថ្ងៃទី ២៨ កក្កដា លោក **ម៉ុល ឌីម** ចុះថ្ងៃទី ៣០ កក្កដា ,លោក **គីម សាខន** ចុះថ្ងៃទី ០១ សីហា និងលោក **ម៉ិត សាន** ចុះថ្ងៃទី ០៣ សីហា ១៩៩៥ ។

សម្រេច

ប្រការ ១ :
១- លោក **ជេត ញ៉ឺន** បុគ្គលិកអធិការដ្ឋានពុទ្ធិកសិក្សា
២- លោក **អ៊ុំ ស៊ុម** បុគ្គលិកនាយកដ្ឋានធម្មការ
៣- លោក **ម៉ុល ឌីម** បុគ្គលិកអគ្គាធិការដ្ឋានពុទ្ធិកសិក្សា
៤- លោក **គីម សាខន** បុគ្គលិកនាយកដ្ឋានធម្មការ
៥- លោក **ម៉ិត សាន** បុគ្គលិកនាយកដ្ឋានធម្មការ

ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់ ។

ប្រការ ២ : បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ជេត ញៀន** ,លោក **អ៊ុម ស៊ុម**, លោក **ម៉ុល ឌីម** , លោក **គីម សាខន** និង លោក **ហ៊ិត លាន** ត្រូវផ្ទេរជូនមន្ទីរធម្មការ និង សាសនា ខេត្តពោធិសាត់ ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនាខេត្តពោធិសាត់ និង អស់លោក ដែលមានឈ្មោះក្នុងប្រការមួយ ត្រូវអនុវត្តតាមប្រកាសនេះរៀងៗ ខ្លួន ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហៀង ចន្ទរិត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសកែតម្រូវ លេខ ១៦៨/៩៥ កធស.ប្រក

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា ។
- បានឃើញប្រកាសលេខ ៣០២ ប្រក ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ចុះថ្ងៃទី ១៥ កក្កដា ១៩៩៥ ។

សំរេច

ប្រការតែមួយ : ធ្វើការកែតម្រូវ ប្រការ ៤ នៃប្រកាសលេខ ១៦១-៩៥ កធស-ប្រក ចុះថ្ងៃទី ៣១ កក្កដា ១៩៩៥ ដែលចែងថា : «មន្ទីរធម្មការ និងសាសនា ខេត្តពោធិសាត់ លោក **ពុធ ខុម** ....រៀងៗ ខ្លួន » ។

សូមអានថា : «មន្ទីរធម្មការ និង សាសនា ខេត្តតាកែវ, លោក ពុធ ខុម ត្រូវអនុវត្តតាមប្រកាសនេះរៀងៗខ្លួន » វិញ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហៀង ខណ្ឌវត្ត

* * *

៧-ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៥១៤ សសរ.កសក

ស្តីពីការប្រគល់សិទ្ធិអោយអ្នកដែលដេញថ្លៃឈ្នួលឡូត៍នេសាទ
បានធ្វើអាជីវកម្មក្នុងឡូត៍នេសាទ ខេត្តកណ្តាល ព្រៃវែង ពោធិសាត់
បាត់ដំបងសំរាប់រដូវនេសាទ ១៩៩៥-៩៦ និង ១៩៩៦-៩៧

* * *

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ចស.រតក ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញក្រឹត្យលេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៨៧ ស្តីពីការជួលដែននេសាទទឹកសាប និង សមុទ្រអោយធ្វើអាជីវកម្ម
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីតួនាទី និង របនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញប្រកាសរបស់ក្រសួងកសិកម្មលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ ស្តីពីកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និង កន្លែងនេសាទបំរុងទុកនៅទឹកសាប
- តាមសំណើរបស់នាយកដ្ឋានជលផលលេខ ១២៧១ ជផ.អជក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ឡូត៍នេសាទតាមបណ្តាខេត្ត ត្រូវបានប្រគល់សិទ្ធិអោយអ្នកដេញថ្លៃបានធ្វើអាជីវកម្មសំរាប់រដូវនេសាទ ១៩៩៥–៩៦ និង ១៩៩៦–៩៧ ដូចមានតារាងភ្ជាប់មកជាមួយ ។

ប្រការ ២ : សេចក្តីសំរេចណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម និង ការិយាល័យជលផល ខេត្តកណ្តាល ព្រៃវែង ពោធិសាត់ បាត់ដំបង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈា សុខ

* * *

-រក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយនៅក្នុងរដ្ឋលេខាធិការដ្ឋានអោយបានល្អ ។

-គ្រប់គ្រងចលនៈវត្ថុ និង ទ្រព្យសម្បត្តិផ្សេងៗទៀត ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋលេខាធិការអោយបានស្ថិតស្ថេរ និងគង់វង់ ។

-គ្រប់គ្រងក្របខ័ណ្ឌពលកម្ម កាន់កាប់បញ្ជីវត្តមាន អវត្តមាន បៀវត្សមន្ត្រីរាជការនៅក្នុងរដ្ឋលេខាធិការដ្ឋាន និងមន្ទីរទំនាក់ទំនងជាមួយសភាខេត្ត ក្រុង អោយបានម៉ត់ចត់ត្រឹមត្រូវ ។

-រៀបចំតារាងបៀវត្សរបស់មន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋាន ។

-លើកគំរោងក្របខ័ណ្ឌបន្ថែម កាត់បន្ថយក្របខ័ណ្ឌ ផ្លាស់ប្តូរ បំពេញមន្ត្រីរាជការជូនកន្លែងខ្វះខាត ។

-តំឡើងបន្ថយថ្នាក់ និង មុខងារដាក់អោយចូលនិវត្តន៍ បាត់បង់សមត្ថភាពពលកម្មដាក់វិន័យបណ្តេញចេញពីក្របខ័ណ្ឌ សរសើរជូនរង្វាន់ចំពោះមន្ត្រីរាជការនៅក្នុងរដ្ឋលេខាធិការដ្ឋាន និង មន្ទីរទំនាក់ទំនង ជាមួយសភា ខេត្ត ក្រុង ។

២- <u>នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ</u> :

នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យមានភារកិច្ចជួយអគ្គនាយកដ្ឋានលើការងារហិរញ្ញវត្ថុ និងគណនេយ្យ ទទួលបន្ទុក :

-អនុវត្តន៍គោលការណ៍សន្សំសំចៃថវិការដ្ឋ ទ្រព្យសម្បត្តិ និងនយោបាយហិរញ្ញវត្ថុរបស់រដ្ឋ ។

-លើកគំរោងផែនការប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ និងគ្រប់គ្រងកាន់កាប់បញ្ជីគណនេយ្យចំណូល ចំណាយថវិការដ្ឋ និង បញ្ជីសារពើភ័ណ្ឌរបស់រដ្ឋលេខាធិការ-ដ្ឋានអោយបានល្អ និងត្រឹមត្រូវ។

-ធ្វើគំរោងបៀវត្ស ប្រាក់ឧបត្ថម្ភ ប្រាក់សោធននិវត្តន៍ ប្រាក់បាត់បង់សមត្ថភាពពលកម្ម របស់មន្ត្រីរាជការនៅក្នុងរដ្ឋលេខាធិការដ្ឋានអោយទាន់ពេលវេលា ។

-ធ្វើរបាយការណ៍ ស្តីពីចំណូលចំណាយថវិកាជូនរដ្ឋលេខាធិការទំនាក់ទំនងជាមួយសភា និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំអោយបានទៀងទាត់ ។

៣– នាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ផ្សព្វផ្សាយ :

នាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ផ្សព្វផ្សាយមានភារកិច្ចជួយអគ្គនាយកដ្ឋានលើការ ងារទំនាក់ទំនង និងផ្សាព្វផ្សាយច្បាប់ ទទួលបន្ទុក :

–ទទួលពាក្យស្នើសុំ បណ្តឹងតវ៉ា បណ្តឹងបរិហារ បណ្តឹងរដ្ឋបាលរបស់ប្រជារាស្ត្រ និង មន្ត្រី រាជការ ហើយជួយសម្រួលបំរើប្រជារាស្ត្រទាំងនោះ ។

–សិក្សាស្រាវជ្រាវ ពាក្យស្នើសុំ បណ្តឹងតវ៉ា បណ្តឹងបរិហារ បណ្តឹងរដ្ឋបាលទាំងនោះ ធ្វើរបាយការណ៍ជូនថ្នាក់លើពិនិត្យសំរេច និងចាត់ការតាមសមត្ថកិច្ច ។

–សិក្សាស្វែងយល់ តាមដានសកម្មភាពរបស់អង្គការសាធារណៈ អង្គការសង្គម ជំរាបជូនរាជរដ្ឋាភិបាល មានវិធានការជួយសំរួល ឬ ណែនាំតាមសភាពការណ៍ជាក់ស្តែង និងជំរាបជូន ប្រជា រាស្ត្រអោយបានយល់ បានដឹង ។

–ធ្វើការបោះពុម្ពឯកសារច្បាប់ ផ្សាព្វផ្សាយគោលនយោបាយរដ្ឋ ផែនការរដ្ឋ ថវិការដ្ឋ ជូនប្រជារាស្ត្រ អង្គការរដ្ឋ អង្គការសង្គម អង្គការសាធារណៈ ។

–សិក្សាស្រាវជ្រាវ សហការ ធ្វើការអប់រំសីលធម៌ វិជ្ជាពលរដ្ឋ និង លទ្ធិប្រជាធិបតេយ្យ ជូនប្រជារាស្ត្រ ។

–សហការផ្សព្វផ្សាយ ពន្យល់ច្បាប់ជូនប្រជារាស្ត្រ ។

៤– <u>នាយកដ្ឋានសិក្សាស្រាវជ្រាវ និង ឯកសារច្បាប់</u> :

នាយកដ្ឋានសិក្សាស្រាវជ្រាវ និង ឯកសារច្បាប់មានភារកិច្ចជួយអគ្គនាយកដ្ឋានលើការងារ សិក្សាស្រាវជ្រាវ និងឯកសារច្បាប់ទទួលបន្ទុក :

–សិក្សាស្វែងយល់ពីការលំបាករបស់រាជរដ្ឋាភិបាលជំរាបជូនសភា ដើម្បីធ្វើការសម្របសម្រួល ។

–សិក្សាស្វែងយល់ពីការលំបាក ការងាយស្រួលក្នុងការអនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាន របស់រាជរដ្ឋាភិបាល ។

–ចូលពិគ្រោះ និង សន្ទនាជាប្រក្រតីជាមួយអគ្គលេខាធិការដ្ឋាន នៃគណៈរដ្ឋមន្ត្រី ដើម្បីយល់ដឹងពីកិច្ចការរបស់រាជរដ្ឋាភិបាល ។

–ចូលពិភាក្សារាល់សេចក្តីព្រាងច្បាប់ ឬ អនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងស្ថាប័ននានា ។

-ស្វែងយល់ពីការលំបាករបស់សភា ឬ ក្រុមសមាជិកសភា ជំរាបជូនរាជរដ្ឋាភិបាល ដើម្បីធ្វើ ការសម្របសម្រួល ។

-រួមប្រាស្រ័យការងារ និងចុះបេសកកម្មតាមមូលដ្ឋាន ជាមួយគណៈកម្មការនានា របស់រដ្ឋសភា ។

-ចូលរួមពិភាក្សាច្បាប់ជាមួយគណៈកម្មការនានារបស់រដ្ឋសភា ។

-តាមដានរាល់សេចក្តីព្រាងច្បាប់ ដែលបានបញ្ជូនទៅសភា និង ធ្វើការសម្រប សម្រួលដាក់ក្នុងរបៀបវារៈ នៃអង្គប្រជុំសភា ។

-ធ្វើទំនាក់ទំនងជាមួយបរទេស ដើម្បីពង្រឹងនឹងពង្រីកបរិយាកាសល្អរវាងរាជរដ្ឋា-ភិបាល និង សភា ។

-សិក្សាស្រាវជ្រាវធ្វើស្ថិតិច្បាប់គ្រប់ផ្នែក (នយោបាយ សង្គម សេដ្ឋកិច្ច វប្បធម៌ ...) ក្នុង និង ក្រៅប្រទេសរៀបចំផែនការលើកគំរោងការងារចូលរួមចំណែកកែលំអ របនាសម្ព័ន្ធរដ្ឋបាលទូទៅ និង ពង្រឹងនីត្យានុកូលភាពលើគ្រប់វិស័យ ។

-សិក្សាស្រាវជ្រាវ សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធបង្កើន និង បង្កើតច្បាប់ថ្មីៗ អោយបានសមស្របតាមតំរូវការនៃការអភិវឌ្ឍន៍ និង ការវិវត្តន៍ នៃសង្គមជាតិ និង សហគមន៍អន្តរជាតិ ។

ប្រកាសនេះនឹងអាចមានការកែប្រែនៅពេលមានច្បាប់បង្កើតក្រសួង និង អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋលេខាធិការដ្ឋាននាពេលខាងមុខ ។

ប្រកាសនេះ ចាប់អនុវត្តពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

នូច កាណុន

* * *

បោះពុម្ពនៅរោងពុម្ពធិស្ថិការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១៤៧០ រៀល